# ទសពិធរាជធម៌

រៀបរៀងដោយ

ភិក្ខុ ចិន ភេន ឥន្ទបញ្ញោ

វត្តពោធិវង្ស ប្រទេសបារាំង

បោះពុម្ពចែកជាធម្មទាន

លើកទី ១ ចំនួន ១៥០០ ក្បាល

# ទសពិធរាជធម៌


រៀបរៀងដោយ

ភិក្ខុ ឃិន ភេន ឥន្ទបញ្ញោ

វាយកុំព្យូទ័រដោយ ភិក្ខុ ពេជ្រ សាម៉ុន
កែអក្ខរាវិរុទ្ធដោយ ភិក្ខុ ឃិន ភេន



បោះពុម្ពចែកជាធម្មទាន
លើកទី១ ចំនួន ១៥០០ ក្បាល

ដោយពុទ្ធបរិស័ទ វត្តពោធិវង្ស
ប្រទេសបារាំង

ព.ស. ២៥៤៩ គ.ស. ២០០៥

# អារម្ភកថា

ក្នុងឱកាស ដែលប្រទេសកម្ពុជាយើង កំពុងធ្វើ ព្រះរាជពិធីព្រះរាជាភិសេក ថ្វាយចំពោះ ព្រះបាទសម្តេច ព្រះបរមនាថនរោត្តម សីហមុនី ឡើងសោយរាជ្យជំនួសព្រះវររាជបិតាតទៅ នៅវត្តពោធិវង្ស ប្រទេសបារាំងនេះ ក៏មានធ្វើបុណ្យកុសល ថ្វាយព្រះពរជ័យសិរីមង្គល ចំពោះព្រះអង្គផងដែរ ។

ពេលព្រឹក : ថ្លែងសេចក្តីប្រកាស ថ្វាយព្រះពរជ័យ និង ស្វាមីភក្តិ នមស្សការ សមាទានសីល ចំរើនបរិត្ត រាប់បាត្រ វេរភត្ត.....
ពេលរសៀល : មានសម្តែងធម្មទេសនា ដោយភិក្ខុ ងិន ភេន...។

ខ្ញុំបានយកធម្មទេសនា ក្នុងពេលនោះ មករៀបរៀងបន្ថែមធម៌ខ្លះទៀត ចងក្រងជាកូនសៀវភៅ ដាក់ឈ្មោះថា ទសពិធរាជធម៌ ។ ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ នឹងបានជាពន្លឺខ្លះ ថ្វាយព្រះរាជា និងជូនលោកអ្នកដឹកនាំ ព្រមទាំង លោកអ្នកអាន ជាពុំខានឡើយ ។

វត្តពោធិវង្ស ថ្ងៃ ១៤ មេសា ២០០៥

ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ

# ធម៌ពិធីរាជធម៌

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### ធម្មទេសនា

អាត្មាភាព សូមចំរើនពរ លោក អ្នក សប្បុរសទាំងអស់គ្នា ។

ថ្ងៃព្រហស្បតិ៍ ទី ២៨ ខែតុលា ២០០៤ នេះ ត្រូវនឹងថ្ងៃពេញបូណ៌មីខែអស្សុជ ឆ្នាំវកឆស័ក ព.ស. ២៥៤៨ ជាថ្ងៃដ៏សំខាន់ក្នុងពុទ្ធសាសនារបស់យើង គឺជាថ្ងៃចេញព្រះវស្សា ។ ក្នុងឱកាសប្រកបដោយនក្ខត្តឫក្សនៃថ្ងៃដ៏សំខាន់នេះ វត្តពោធិវង្ស (ប្រទេសបារាំង) យើង បានរៀបចំកម្មវិធីធ្វើបុណ្យមួយដ៏ខ្ពង់ខ្ពស់ គឺយើងធ្វើបុណ្យដើម្បីថ្វាយព្រះពរជ័យ ចំពោះព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ដែលព្រះអង្គត្រូវឡើងគ្រងរាជ្យជំនួសព្រះវររាជបិតា តរៀងទៅ ។ អញ្ចឹង ថ្ងៃហ្នឹង យើងទាំងអស់គ្នា មិនមែនគ្រាន់តែធ្វើបុណ្យធ្វើទាន តាមប្រពៃណីថ្ងៃសីល ថ្ងៃចេញវស្សាប៉ុណ្ណោះទេ គឺយើងធ្វើបុណ្យដ៏ប្រសើរវិសេសមួយ ដូចបានជម្រាបមកហើយនេះ ។

លោក អ្នក សប្បុរស បានជ្រាបហើយ ពីព្រឹកមិញ យើងបានធ្វើសេចក្តីថ្លែងប្រកាសថ្វាយព្រះពរជ័យ នមស្សការ សមាទានសីល រាប់បាត្រ វេរភត្ត... សព្វគ្រប់ទាំងអស់ ។ ដល់មកពេលរសៀលនេះ នៅពេលដែលយើងសម្តែងធម៌ទេសនា ទេសនាថ្ងៃនេះ ក៏ក្នុងន័យថ្វាយព្រះពរជ័យ ចំពោះព្រះករុណាថ្មី ដូចជាយើងបានធ្វើពីព្រឹកមិញ

នោះដែរ ។ ហេតុនេះ សូម លោក អ្នក សប្បុរស តាំងចិត្តស្តាប់ព្រះធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដោយសេចក្តីគោរព ចុះ អាត្មាភាព នឹងសម្តែងធម៌ទេសនា ល្មមសមគួរដល់រឿងរ៉ាវ និង ពេលវេលា ឰដ៏គ្រាឥឡូវនេះ សូមចំរើនពរ ។

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស**

សូមនមស្សការចំពោះ ព្រះមានព្រះភាគ អរហន្ត សម្មាសម្ពុទ្ធ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និង ព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

**គារវោ ច និវាតោ ច ឯតម្មង្គលមុត្តមំ**

ធម្មទេសនា ថ្ងៃនេះ អាត្មាភាព បានលើកយកពុទ្ធភាសិត ក្នុងមង្គលសូត្រ ដែលមានសម្តែងទុកក្នុងគម្ពីរ សុត្តន្តបិដក ខុទ្ទក-និកាយ មកតាំងទុកជានិក្ខេបបទ –

**គារវោ ច និវាតោ ច ឯតម្មង្គលមុត្តមំ**

ការគោរពផង ការឱនលំទោនផង ជាមង្គលដ៏ឧត្តម ។

មង្គលដ៏ឧត្តម មានគោលធម៌ ជាគ្រឹះជាហេតុសម្រាប់ឲ្យយើង បដិបត្តិច្រើនណាស់ ប៉ុន្តែ ក្នុងពេលនេះ អាត្មាភាព លើកយកមក តែ ២ គោលធម៌ទេ គឺការគោរព និង ការឱនលំទោន ។ សេចក្តីគោរពឱនលំទោននេះ ជាសីលធម៌ ជាចរិយាធម៌មួយដ៏ល្អ ។ ជន

អ្នកមានការចេះដឹង មានវប្បធម៌ អរិយធម៌ខ្ពស់ គេតែងនាំគ្នាបដិបត្តិជាទំនៀមទម្លាប់ជាប់ជាប្រពៃណីតរៀងមក ។

ព្រះសម្មាសម្ពុទ្ធ បរមគ្រូរបស់យើង ទ្រង់ជ្រាបរឿងនេះច្បាស់ណាស់ ព្រះអង្គបានត្រាស់សម្តែងថា ធម៌ ២ ប្រការនេះ បើគេមិនគោរព មិនបដិបត្តិឲ្យល្អទេ នឹងទៅជាអព្វមង្គល ប៉ុន្តែ បើគេចេះគោរព បដិបត្តិឲ្យបានល្អជិតដល់ នឹងបានបុណ្យកុសល ហើយជាមង្គលដ៏ឧត្តមផង ។

គារវោ ការគោរពមានច្រើនបែប តាមប្រពៃណីនៃជាតិនីមួយៗ គោរពដោយការថ្វាយបង្គំ ឬសំពះ គោរពដោយការក្រោកទទួល គោរពដោយការជូនអាសនៈ គោរពដោយការជៀសផ្លូវជាដើម ។ គោរពជាអន្តរជាតិ ជាសាកល គេធ្វើយ៉ាងម៉េច លោកអ្នកជ្រាបហើយ មានការចាប់ដៃគ្នាជាដើម ។

និវាតោ ការឱនលំទោន គឺភាពទន់ភ្លន់ សុភាពរៀបរយ មិនមានទិដ្ឋិមានះ ប្រកាន់ពូជពង្សវង្សត្រកូល ប្រកាន់ថាអញជានាម៉ឺនអញជាអ្នកមានទ្រព្យស្តុកស្តម្ភ អញជាអ្នកចេះដឹងច្រើនជាដើម គេមានអាកប្បកិរិយាដូចគេដូចឯង ។ និវាតោ តាមបាលី ប្រែថា មិនមានខ្យល់ មិនប៉ោង បើមានខ្យល់ បើប៉ោង មិនទន់ទេ ព្រោះមិនមានខ្យល់ ទើបវាទន់ បានជាគេប្រែថា ទន់ភ្លន់ ឬឱនលំទោន ។

ការគោរព និង ឱនលំទោននេះ ជាមង្គលដ៏ឧត្តម បានសេចក្តីថា បើគេចេះគោរព ឱនលំទោនល្អហើយ គេនឹងបានទូវសិរីសួស្តី

សុខសប្បាយ ចំរើនរុងរឿង ថ្កុំថ្កើងឡើងជាលំដាប់ទៅ ។ មិនតែប៉ុណ្ណោះ ក្នុងបុញ្ញកិរិយាវត្ថុ ព្រះសម្មាសម្ពុទ្ធ ទ្រង់ចាត់ទុក អបចាយនធម៌ ការគោរពឱនលំទោននេះ ជាវិធីមួយនាំឲ្យកើតបុណ្យកុសលទៀតផង។ និងក្នុងអនុមោទនាគាថា លោកពោលថា ពរទាំងឡាយ ៤ ប្រការគឺ អាយុ១ វណ្ណៈ១ សុខៈ១ ពលៈ១ រមែងចំរើនកើតកើនជានិច្ច ដល់បុគ្គលអ្នកចេះគោរពឱនលំទោន ចំពោះបុគ្គលដែលគួរគោរពបូជា មានចាស់ព្រឹទ្ធាចារ្យជាដើម ។ នេះ បញ្ជាក់ថា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម លោកលើកតម្កើងការគោរពឱនលំទោននេះ ជាសេចក្តីល្អមួយដ៏ប្រសើរ ដែលមនុស្សត្រូវតែបដិបត្តិឲ្យបានល្អ ។

ខ្មែរយើងពីដើម គេមានរបៀបរបប សណ្តាប់ធ្នាប់ គេចេះគោរព ឱនលំទោនគ្នាសមរម្យល្អណាស់ ប៉ុន្តែ ខ្មែរសម័យក្រោយ ដោយសេពគប់នឹងបរទេស ភ្ញាក់ផ្អើលប្រជាធិតេយ្យ សេរីភាព សម-ភាព ជ្រុលពេកទៅ មិនសូវចេះរបៀបរបបសណ្តាប់ធ្នាប់ មិនចេះគោរព ឱនលំទោនទេ ។ ខ្ញុំឮថា សព្វថ្ងៃ គេគិតតែពីជេរគ្នា ប្រមាថគ្នា តាមវិទ្យុ តាមទូរទស្សន៍ និង តាមអាំងទែរណែតទៀតផង ។ សូមជម្រាបថា បើយើងថយការគោរពឱនលំទោន ប្រែថា យើងថោកហើយ មិនមែនមានតម្លៃទេ កុំច្រឡំ ។

ជាតិណា សាសនាណា ក៏មានសីលធម៌ ចរិយាធម៌ របស់គេដែរ គេតែងតែបង្ហាត់បង្រៀនគ្នា ឲ្យចេះគោរព ឱនលំទោន **បូជកោ លភតេ បូជំ** យើងបូជាគេ គេបូជាយើង **វន្ទកោ បដិ**

**ទន្ទនំ** យើងថ្វាយបង្គំគេ គេថ្វាយបង្គំយើងវិញ មើលតែរូបក្នុងកញ្ចក់ឆ្លុះយល់ហើយ បើយើងញញឹម វាញញឹមតបវិញ បើយើងមុខក្រញូវ វាធ្វើមុខក្រញូវដាក់យើងវិញដែរ ។

ខ្មែរយើងសព្វថ្ងៃ មិនដឹងជាទៅដល់ណាហើយទេ រឿងសក្តិយស និង ការគោរពឱនលំទោននេះ ។ ខ្ញុំចេះតែនឹកគិតថា គេបានសក្តិយសមកពីណាមកចែកគ្នាច្រើនសន្ធឹកម្ល៉េះ បានមកពីម៉ែឪគេ ឬ បានមកពីជាតិ សាសនាឲ្យ បើបានមកពីជាតិសាសនាឲ្យ ត្រូវឲ្យដល់មនុស្សអ្នកបំរើជាតិសាសនាពិតៗ ។ ប៉ុន្តែ ឃើញតែគេឲ្យបងប្អូនគេ បក្សពួកគេ ឬ អ្នកដែលមានប្រាក់ឲ្យគេ ពួកអស់នេះ ប្រហែលជាមិនសូវស្រឡាញ់ជាតិ សាសនា ពិតប្រាកដទេ។ ឯអ្នកដែលស្រឡាញ់ជាតិ សាសនា ពិតប្រាកដ ប្រសិនបើបានទទួលខ្លះ ប្រហែលជាកាកៗសំណល់ប៉ុណ្ណោះ ។

សព្វថ្ងៃនេះ អ្នកដែលមានសក្តិយស មានចំនួនច្រើនពេកពេញហៀររតិរតាក់ គ្រាន់តែថ្នាក់ឯកឧត្តម ឬ...១ដុំនោះ រាប់មិនអស់ទៅហើយ ។ ឯការគោរព ឱនលំទោនវិញ ដោយចង់ឲ្យគេគោរពខ្លាំងពេក ក៏ពេញហៀររតិរតាក់ធ្លាក់តាមថ្នល់តាមផ្សារ គួរខ្មាសអៀន រឹងខ្លួន ។ រីឯអ្នកមិនចេះគោរពឱនលំទោនវិញ ក៏និយាយលែងដឹង ខុសត្រូវសមគួរហើយ សូម្បីតែមហាក្សត្ររបស់ខ្លួន ក៏គេនិយាយប្រើ ពាក្យថា គាត់ៗ ដូចជាមនុស្សសាមញ្ញធម្មតាដែរ ។ ដូចនេះ កុំទុកឲ្យថោកតទៅទៀត ល្មមរៀបចំ ល្មមបង្ហាត់បង្រៀនគ្នា

ឲ្យថ្លៃថ្នូរឡើងវិញហើយ ខ្មាសជាតិគេឯទៀតផង ។

## បុគ្គលជាទីគោរព

ជាទូទៅ បុគ្គលអ្នកចំរើនដោយវ័យក្តី អ្នកចំរើនដោយគុណធម៌ក្តី ឬ កន្លែងខ្លះគេរាប់បញ្ចូល អ្នកចំរើនដោយជាតិ មានជាតិក្សត្រជាដើមក្តី ចាត់ទុកជាបុគ្គលគួរគោរព ។ ប៉ុន្តែ បើនិយាយជាពួកលោកពោលថា បុគ្គលដែលយើងត្រូវគោរពមាន ៤ ពួកគឺ : -

១-មាតាបិតា ជាបុព្វការីរបស់បុត្រធីតា ព្រោះលោកបានបង្កើតយើងផង បានចិញ្ចឹម និង ទំនុកបំរុងយើងសព្វបែបយ៉ាងផង ។ បុត្រធីតា ត្រូវតែគោរព និង ចិញ្ចឹមលោកវិញ ឲ្យបានល្អ ។

២-គ្រូ អាចារ្យ លោកបានបង្ហាត់បង្រៀនចំណេះវិជ្ជាផ្សេងៗដល់យើងក្តី លោកបានបំបួសយើងក្តី ចាត់ទុកជាបុព្វការីជន មានគុណដល់យើង យើងត្រូវតែគោរពលោកវិញឲ្យបានល្អ ។

៣-ព្រះសាស្តា អ្នកបង្កើតសាសនាក្តី ព្រះអរហន្ត ឬ ព្រះសង្ឃអ្នកគ្រប់គ្រង អ្នកផ្សាយសាសនាក្តី ចាត់ជាបុព្វការីរបស់ពួកបរិស័ទ ព្រោះលោកបានបង្ហាត់សីលធម៌ និង អរិយធម៌ដល់យើង យើងត្រូវតែគោរពលោកឲ្យបានល្អ ។

៤-ព្រះមហាក្សត្រ ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រី ចាត់ជាបុព្វការី របស់ប្រជាជន ព្រោះលោកបានមើលសុខទុក្ខ និង ជួយសង្គ្រោះយើងឲ្យមានចំណេះវិជ្ជា និង មានជីវភាពខ្ពង់ខ្ពស់ថ្លៃថ្នូរឡើង ។

យើងជាប្រជាជន ត្រូវតែគោរពលោកវិញឲ្យបានល្អ សូម្បីតែព្រះសង្ឃក៏ជាប្រជាជនរបស់លោកដែរ ត្រូវតែគោរពលោកឲ្យបានសមរម្យវិញ គ្រាន់តែមិនចាំបាច់ធ្វើកាយវិការសំពះ ឬថ្វាយបង្គំតបតែប៉ុណ្ណោះ ។

ឥឡូវនេះ ស្រុកយើងគេកំពុងតែធ្វើព្រះរាជពិធី រាជាភិសេកព្រះករុណាថ្មី ។ ដ្បិតព្រះករុណា នរោត្តម សីហនុ មានព្រះជន្ម ៨២ ព្រះវស្សាហើយ ជរាព្រះអង្គណាស់ហើយ ព្រះអង្គសុំចូលនិវត្តទើបមានពិធីផ្ទេររាជសម្បត្តិ ថ្វាយព្រះរាជបុត្រព្រះនាម នរោត្តម សីហមុនី ឡើងសោយរាជ្យជំនួសព្រះបិតា តរៀងទៅ ។ នេះ ជាឱកាសមួយដ៏ប្រសើរ ដែលយើងជាប្រជាជន ត្រូវសម្តែងស្វាមីភក្តិ ថ្វាយសេចក្តីគោរព និង ថ្វាយព្រះពរជ័យសិរីមង្គលចំពោះព្រះអង្គ ។ បានឮថា នៅប្រទេសកម្ពុជាយើង គេធ្វើបុណ្យ ៣ ថ្ងៃ៣ យប់ គ្រប់វត្តអារាម វាយជួង ទូងភេរី ថ្វាយព្រះពរជ័យព្រះអង្គយ៉ាងគគ្រឹកគគ្រេង ។ ការសម្តែងសេចក្តីគោរព និង ថ្វាយព្រះពរជ័យ សិរីមង្គលនេះ ជាទំនៀមទម្លាប់មួយដ៏ល្អ និង ជាមង្គលដ៏ឧត្តម ដែលយើងត្រូវខំថែរក្សា និង បដិបត្តិ តរៀងទៅ ។

ការសម្តែងសេចក្តីគោរព និង ស្វាមីភក្តិ មិនមែនធ្វើត្រឹមតែពិធីប៉ុណ្ណោះ ហើយទៅដេកសម្ងំស្ងៀម ធ្វើមិនដឹងមិនឮអ្វីនោះទេ យើងត្រូវបំពេញតួនាទីយើងជាប្រជាជនល្អ និង ត្រៀមខ្លួនជានិច្ចដើម្បីរួមចំណែកក្នុងកិច្ចការពារ និង សាងប្រទេសជាតិរបស់ខ្លួន គ្រប់កាលៈទេសៈទាំងអស់ បើត្រូវលះបង់ទ្រព្យ ក៏លះបង់ទ្រព្យ បើត្រូវលះបង់

កម្លាំង ក៏លះបង់កម្លាំង រហូតដល់មានពេលខ្លះ ត្រូវហ៊ានលះបង់ជីវិត ដើម្បីជាតិ និង សាសនារបស់ខ្លួន ។

ចំណែករដ្ឋាភិបាល នាម៉ឺនមុខមន្ត្រី ទាហាន ស៊ីវិល គ្រប់ក្រសួងក្តី មេគណៈបក្សនយោបាយទាំងឡាយក្តី ត្រូវថ្វាយព្រះពរជ័យ និង ស្វាមីភក្តិ ចំពោះព្រះមហាក្សត្ររបស់ខ្លួនឲ្យពិតប្រាកដ កុំធ្វើគ្រាន់តែជាពិធីដូចយកជីររោយមុខ... ត្រូវឈប់ឈ្លោះគ្នា ត្រូវឈប់ស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន ឬប្រយោជន៍បក្សរបស់ខ្លួន ហើយងាកមករួបរួមសាមគ្គីគ្នា ក្រោមម្លប់ពោធិសម្ភារនៃព្រះមហាក្សត្រ ដើម្បីសាងជាតិសាសនារបស់យើង ឲ្យបានថ្កុំថ្កើងរុងរឿងឡើងវិញជាប្រញាប់ ។

## ព្រះរាជា

ព្រះរាជា ខ្មែរយើងប្រែថា ស្តេច ។ អ្នកខ្លះគេថា ស្តេចមកពីស៊ីដាច់ គឺឈ្នះគេ ធំជាងគេ បានជាគេហៅថា ស៊ីដាច់ ស្តេច។ ព្រះរាជា ឬស្តេច កើតមកពីណា ? ក្នុងគម្ពីរ សុត្តន្តបិដក ទីឃនិកាយ អគ្គញ្ញសូត្រ តំណាលថា ស្រុកពីដើមអាហារភោជនសម្បូណ៌ណាស់ មិនខ្វះខាតអ្វីទេ ដល់ពេលត្រូវការទើបគេទៅយកមក ។ ក្រោយមក អ្នកខ្ជិលដោយមិនចង់ចេញទៅយករឿយៗ ក៏ប្រមូលស្រូវអង្ករមកទុកក្នុងផ្ទះរបស់ខ្លួន ប្រមូលច្រើនឡើង លោភច្រើនឡើង កម្មសិទ្ធិច្រើនឡើង ធ្វើឲ្យអ្នកដទៃខ្វះខាត ទុក្ខលំបាកក្តៅក្រហាយ ។ អាស្រ័យហេតុនេះ ទើបមហាជនសម្រេច ជ្រើសរើស

មនុស្សឲ្យជួយមើល សុខ ទុក្ខ ខុស ត្រូវ របស់ពួកគេ ។ អ្នកមើល សុខ ទុក្ខ ខុស ត្រូវ នោះ គេហៅថា មហាជនសម្មតោ ប្រែថា មនុស្សដែលមហាជនសន្មត ។ ហៅខ្ចីថា មហាសម្មតោ ក្លាយមកទៀតជា មហាសម្មតិ ខ្ពស់ឡើងថែមទៀតជា មហាសម្មតិទេព ។

ស្រុកពីដើម របររបស់ប្រជាជន គឺធ្វើស្រែចំការ ខេត្តានំ អធិបតិ អ្នកជាអធិបតី ជាធំ ក្នុងកិច្ចការនៃស្រែចំការ គេហៅថា ខត្តិយៈ ឬ ក្សត្រិយៈ ខ្មែរយើងប្រែថា ស្តេចដែរ ។ ធម្មេន បរេសំ រញ្ជេតិ ស្តេចកាលបើចេះមើល សុខ ទុក្ខ រកយុត្តិធម៌ឲ្យប្រជាជនបាន គេហៅថា ព្រះរាជា ប្រែថា អ្នកញ៉ាំងប្រជាជនឲ្យរីករាយសប្បាយតាមធម៌។ ឯពួកនាម៉ឺនទាំងឡាយ ក៏កើតមានឡើងដើម្បីជួយព្រះរាជា បម្រើប្រជាជន ។ បើតាមន័យនេះ ព្រះរាជា មិនមែនជាមនុស្សមានពូជពិសេសមកពីណាទេ គឺជាមនុស្សធម្មតាហ្នឹងឯង ដែលប្រជាជនគេជ្រើសរើសសន្មតឡើងឲ្យធ្វើជាអ្នកជួយមើល សុខ ទុក្ខ ឲ្យគេបានសុខសប្បាយ ដូចជាគេជ្រើសរើសប្រធានាធិបតីសព្វថ្ងៃនេះដែរ ។ ឯការដែលបង្កើតច្បាប់ឲ្យឡើងសោយរាជ្យតកូនចៅ ជារឿងដែលគេកែច្នៃក្រោយ។ ដូចនេះ គួរតែវិលទៅរកវិធីដើម គឺជ្រើសរើសវិញ ត្រូវនឹងពាក្យដែលគេនិយាយសព្វថ្ងៃថា រដ្ឋាភិបាលរបស់ប្រជាជន ដោយប្រជាជន ដើម្បីប្រជាជន ។ រដ្ឋាភិបាល ត្រូវតែបំរើប្រជាជន មិនត្រូវក្លែងបន្លំធ្វើធំ បៀតបៀនជិះជាន់រាស្ត្រ រកផលប្រយោជន៍ដើម្បីសេចក្តីសុខសប្បាយផ្ទាល់ខ្លួន និង បក្សពួកទេ ។

# ធម៌របស់ព្រះរាជា

ព្រះរាជា និង រដ្ឋាភិបាល មិនមែនដឹកនាំប្រទេសជាតិ សុទ្ធតែបានសុខចំរើន គ្រប់ព្រះអង្គនោះទេ ។ រជ្ជកាលខ្លះ មានបាត់ទឹកបាត់ដី កើតភ័យវិបត្តិ វិនាសអន្តរាយ ក្តៅក្រហាយពេញផ្ទៃប្រទេស។ ប៉ុន្តែ មានព្រះរាជាអង្គខ្លះ ដូចជាព្រះបាទជ័យវរ្ម័នទី ៧ ជាដើម ព្រះអង្គគិតដល់សុខទុក្ខរបស់ប្រជាជន ដូចជាសុខទុក្ខផ្ទាល់ព្រះអង្គ ម៉្លោះហើយ ព្រះអង្គដឹកនាំប្រទេសជាតិ បានសុខចំរើនរុងរឿងណាស់ មិនត្រឹមតែមនុស្សទេ សូម្បីតែសត្វក៏បានសុខដែរ ។ ដូចនេះ ព្រះរាជា និង រដ្ឋាភិបាល ត្រូវមានចំណេះវិជ្ជាឲ្យច្រើន ត្រូវមានប្រាជ្ញាឲ្យវាងវៃ និងត្រូវមានគុណធម៌ក្នុងខ្លួនឲ្យច្រើនផង ទើបអាចជួយសាងសេចក្តីសុខចំរើនឲ្យប្រជារាស្ត្របាន ។ ធម៌របស់ព្រះរាជា មានច្រើនប្រការ ខ្ញុំនឹងពណ៌នាខ្លះដូចតទៅ –

## ព្រហ្មវិហារធម៌

ព្រហ្មវិហារធម៌ ធម៌ជាទីនៅរបស់ព្រះព្រហ្ម ធម៌របស់ព្រះព្រហ្ម ធម៌របស់អ្នកធំ ធម៌របស់អ្នកដឹកនាំ មាន៤ យ៉ាងគឺ :-

១-**មេត្តា** សេចក្តីស្រឡាញ់រាប់អាន ។

២-**ករុណា** សេចក្តីអាណិតអាសូរ ជួយដោះស្រាយទុក្ខលំបាក។

៣-**មុទិតា** សេចក្តីរីករាយក្នុងពេលដែលគេបានសុខចំរើន ។

៤-**ឧបេក្ខា** តាំងចិត្តជាកណ្តាលចំពោះគេទាំងអស់មិនលំអៀង។

បើអ្នកដឹកនាំ មានចិត្តប្រកបដោយព្រហ្មវិហារធម៌ហើយ ប្រទេសជាតិ និង ប្រជាជន នឹងកើតមានសេចក្តីត្រជាក់ត្រជុំក្សេមក្សាន្ត ចំរើនល្អលាស់ ជាពុំខានឡើយ ។

## អគតិធម៌

អគតិ សេចក្តីលំអៀង មាន ៤ យ៉ាងគឺ :-

១- **ឆន្ទាគតិ** សេចក្តីលំអៀងព្រោះស្រឡាញ់ ។

២- **ទោសាគតិ** សេចក្តីលំអៀងព្រោះស្អប់ ។

៣- **មោហាគតិ** សេចក្តីលំអៀងព្រោះល្ងង់ ។

៤- **ភយាគតិ** សេចក្តីលំអៀងព្រោះខ្លាច ។

អ្នកធំ អ្នកដឹកនាំ ត្រូវមានសេចក្តីស្មោះត្រង់ ត្រូវមានយុត្តិធម៌ កុំគប្បីលំអៀងព្រោះស្រឡាញ់ ឬព្រោះស្អប់ សូម្បីតែលំអៀងព្រោះខ្លាចគេ ឬលំអៀងព្រោះសេចក្តីល្ងង់របស់ខ្លួន ក៏ជាធម៌មិនល្អទាំងអស់ ។ ព្រះពុទ្ធ ទ្រង់យសសម្តែងថា អ្នកដើរតាមផ្លូវអគតិធម៌ទាំង ៤ នេះ ដូចជាព្រះចន្ទខាងរនោច គឺចេះតែងងឹតទៅៗ វិនាសហិនហោចទៅជាលំដាប់ គេគប្បីឈប់អគតិធម៌ជាប្រញាប់ ទើបអាចត្រឡប់ភ្លឺស្វាងឡើងវិញបាន ។

## សង្គហធម៌

សង្គហធម៌ ធម៌សម្រាប់សង្គ្រោះគ្នា ក្នុងបាលីប្រើពាក្យថា សង្គហវត្ថុ មាន ២ យ៉ាងគឺ :-

១- **សង្គហវត្ថុ** សំរាប់មនុស្សទូទៅ ។

២- **សង្គហវត្ថុ** សំរាប់ព្រះរាជា ។

## សង្គហវត្ថុ សំរាប់មនុស្សទូទៅ

សង្គហវត្ថុ ប្រែថា វត្ថុសំរាប់សង្គ្រោះ ឬវិធីសំរាប់សង្គ្រោះ មាន ៤ យ៉ាងគឺ :-

១-**ទាន** ការឲ្យ ឲ្យជាទ្រព្យរបស់ ឬ ឲ្យជាចំណេះវិជ្ជា ។

២-**បិយវាចា** ពាក្យសំដីពិរោះផ្អែមល្ហែម និង ពាក្យសំដីមានខ្លឹមសារ មានប្រយោជន៍ ។

៣-**អត្ថចរិយា** ការប្រព្រឹត្តិជាប្រយោជន៍ គឺយកខ្លួនឯងទៅធ្វើប្រយោជន៍ ដូចជាជួយខ្វល់ខ្វាយកិច្ចជាសាធារណប្រយោជន៍ក្តី ជួយប្រព្រឹត្តឲ្យមានសីលធម៌ ចរិយាធម៌ កាន់តែល្អឡើងក្តី ។

៤-**សមានត្តតា** ជាអ្នកទុកដាក់ខ្លួនស្មើ មិនខ្ពស់ពេក មិនទាបពេក អ្នកតូចក៏ចូលបាន អ្នកធំក៏រាប់អានកើត ។

អ្នកសង្គមសង្គ្រោះ កុំគិតខំរកតែទ្រព្យរបស់ (ទេយ្យវត្ថុ) តែម្យ៉ាងមកជួយសង្គ្រោះអ្នកដទៃ ។ ធ្វើយ៉ាងនេះ ពិតជាមិនបានជោគជ័យទេ ។ គេត្រូវរៀនបដិបត្តិតាមវិធីសង្គ្រោះទាំង ៤ យ៉ាងនេះឲ្យសព្វគ្រប់ ទើបការសង្គ្រោះនោះមានប្រសិទ្ធិភាព ។

## សង្គហវត្ថុសំរាប់ព្រះរាជា

សង្គហវត្ថុសំរាប់ព្រះរាជា ហៅថា រាជសង្គហវត្ថុ

រាជសង្គហវត្ថុ ប្រែថា វត្ថុសំរាប់សង្គ្រោះនៃព្រះរាជា ឬ វិធីសង្គ្រោះនៃព្រះរាជា មាន ៤ យ៉ាងគឺ :-

១-**សស្សមេធៈ** ឆ្លាតក្នុងការចែកពូជ ពូជស្រូវ ពូជដំណាំផ្សេងៗ ព្រមទាំងវិធីការពារ និង បង្កើនផលិតផល ។

២-**បុរិសមេធៈ** ឆ្លាតក្នុងការទំនុកបំរុងកងទ័ព និង អ្នករាជការទូទៅ ព្រមទាំងជួយអ្នកពូកែ អ្នកល្អ ឲ្យកាន់តែល្អតលាស់ប្រសើរឡើង ។

៣-**សម្មាបាសះ** ឆ្លាតក្នុងការជួយអ្នកប្រកបមុខរបរផ្សេងៗ ព្រមទាំងឲ្យខ្ចីបុលទ្រព្យយកទៅធ្វើជាដើមទុនផង ។

៤-**វាជបេយ្យ** ឆ្លាតក្នុងការប្រើពាក្យសំដី និយាយពិរោះ មានហេតុផល ងាយយល់ ស្តាប់ទៅហើយភ្លឺប្រាជ្ញា ភ្ញាក់គំនិត ។

ពួកព្រាហ្មណ៍ ចូលចិត្តបូជាយញ្ញ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន បានកែរាជសង្គហវត្ថុ ៤ នេះ ទៅជា មហាយញ្ញ ៥ គឺ :-

១-**អស្សមេធៈ** សម្លាប់សេះបូជាយញ្ញ ។

២-**បុរិសមេធៈ** សម្លាប់មនុស្សបូជាយញ្ញ ។

៣-**សម្មាបាសះ** បោះឈើឲ្យចូលទៅក្នុងរង់អន្ទាក់ធ្លាក់ចុះក្នុងកន្លែងបូជាយញ្ញ ។

៤-**វាជបេយ្យ** ពិធីផឹកដើម្បីកម្លាំងពលំ ឬ ជ័យជំនះ ។

៥-**និរគ្គឡៈ** ឬ **សព្វមេធៈ** មិនមានគន្លឹះ ឬ មិនមានកំណត់សម្លាប់គ្រប់មុខ ដើម្បីបូជាយញ្ញ ។

## នាយកធម៌

នាយកធម៌ ធម៌របស់នាយក របស់អ្នកដឹកនាំ មាន ៦ យ៉ាងគឺ:

១-**ខមា** សេចក្តីអត់ធន់ ។

២-**ជាគរិយៈ** សេចក្តីភ្ញាក់រលឹក និង ប្រុងប្រយ័ត្ន ។

៣-**ឧដ្ឋានៈ** សេចក្តីឧស្សាហ៍ ខ្មីឃ្មាត ។

៤-**សំវិភាគៈ** ការចែករំលែកដល់អ្នកដទៃ ។

៥-**ទយា** សេចក្តីអាណិតអាសូរ ។

៦-**ឥក្ខណា** ការរំពៃមើលខុសត្រូវរឿយៗ ។

អ្នកដឹកនាំ ទោះបីធំ ឬ តូច ត្រូវតែមាននាយកធម៌នេះ បើមិនមានធម៌នេះ កុំចង់ដឹកនាំ ។

## អបរិហានិយធម៌

ព្រះមានព្រះភាគ សម្តែងប្រាប់អានន្ទថា បើស្តេចវជ្ជី នៅតែប្រព្រឹត្តតាម អបរិហានិយធម៌ ស្តេចវជ្ជី និង ដែនវជ្ជី នៅតែចំរើនរុងរឿង មិនមានសេចក្តីសាបសូន្យទេ ។ អបរិហានិយធម៌ មាន ៧ ប្រការគឺ : -

១-ឧស្សាហ៍ប្រជុំគ្នារឿយៗ ។ បានសេចក្តីថា កុំអត្តនោម័តិ កុំមានតែអញ ឲ្យចេះស្តាប់គេផង ។

២-ព្រមព្រៀងគ្នាប្រជុំ ព្រមព្រៀងគ្នាបិទការប្រជុំ និង ព្រមព្រៀងគ្នាធ្វើកិច្ចដែលគួរធ្វើ ។ ឧទាហរណ៍ ការពារប្រទេសជាតិ និង កសាងប្រទេសជាតិជាដើម ។

៣-មិនបញ្ញត្តច្បាប់ ដែលមិនបានបញ្ញត្ត មិនលុបច្បាប់ដែលបានបញ្ញត្តហើយ ធ្វើតាមខបញ្ញត្តដែលមានមកហើយ ។ បានសេចក្តីថា ការបញ្ញត្តច្បាប់ ឬ លុបច្បាប់ដើម្បីផលប្រយោជន៍ជាតិ មិនមានការហាមឃាត់ទេ ប៉ុន្តែ ក្នុងទីនេះ ហាមមិនឲ្យបញ្ញត្ត ឬ មិនឲ្យលុបច្បាប់ ដើម្បីផលប្រយោជន៍ខ្លួន ឬ ក្រុមខ្លួន ។

៤-លោក អ្នក ឯណា ដែលជាចាស់ទុំ ត្រូវគោរព លោក អ្នក នោះ ត្រូវជឿស្តាប់ លោក អ្នក នោះ ។ គឺ ត្រូវគោរពតាមច្បាប់ទម្លាប់ទំនៀមផង ត្រូវស្តាប់យោបល់របស់ចាស់ទុំផង ។

៥-ត្រូវគោរព ស្ត្រី គោរពកុមារី... ។ គឺត្រូវឲ្យតម្លៃទៅស្ត្រីជាពិសេស កុំយកស្រី ឬ កុមារី មករំលោភលេងសប្បាយ តាមអំពើពាលារបស់ខ្លួន ។

៦-ត្រូវគោរពចេតិយ ដែលមានមកហើយ និង មិនត្រូវប៉ះពាល់ផលប្រយោជន៍របស់ចេតិយ ។ ចេតិយ គឺកន្លែងគោរព ជាទីកន្លែងក្តី ជាដើមឈើក្តី ជាសំណង់ផ្សេងៗក្តី ឬ ជាវត្តអារាមក្តី ត្រូវតែទុកជាទីគោរព មិនត្រូវបំផ្លាញ ឬ បៀតបៀនដោយប្រការណាមួយឡើយ ។ ឯផលប្រយោជន៍របស់ចេតិយវិញ ក៏មិនត្រូវប៉ះពាល់ ឬ បង្វែរទៅធ្វើអ្វីផ្សេង តាមអំពើចិត្តរបស់ខ្លួនឡើយ ។

៧-ត្រូវថែរក្សាការពារ ព្រះអរហន្តទាំងឡាយ (ពួកអ្នកបួស) ដែលមកហើយ សូមឲ្យគង់នៅជាសុខចុះ ដែលមិនទាន់បានមក ក៏អាចនិមន្តមកបាន ។

# ទសពិធរាជធម៌

ទសពិធរាជធម៌ ប្រែថា ធម៌របស់ព្រះរាជា ១០ យ៉ាង ។

ពាក្យថា ព្រះរាជា ក្នុងទីនេះ បើមើលតាមព្យញ្ជនៈ សំដៅយកស្តេចគ្រងរាជ្យ តែ ១ អង្គប៉ុណ្ណោះ ប៉ុន្តែ បើពិចារណាតាមអត្ថៈ សំដៅយក អ្នកគ្រប់គ្រង អ្នកដឹកនាំ ជាស្តេចក្តី ជាប្រធានាធិបតីក្តី ជានាយករដ្ឋមន្ត្រីក្តី ឬ រដ្ឋមន្ត្រីជាដើមក្តី ត្រូវបដិបត្តិទសពិធរាជធម៌ ១០យ៉ាងនេះ ដូចគ្នាទាំងអស់ ។ ទសពិធរាជធម៌ ១០ យ៉ាងនោះគឺៈ-

១-**ទានៈ** ការឲ្យ ឲ្យទ្រព្យដល់បុគ្គលម្នាក់ៗក្តី ឲ្យទ្រព្យដើម្បីសាងសាធារណប្រយោជន៍ក្តី ។

២-**សីលៈ** រក្សាកាយវាចារៀបរយ កាន់សីល ៥ ក្តី កាន់សីលឧបោសថក្តី ។

៣-**បរិច្ចាគៈ** អ្នកខ្លះគេថា បរិច្ចាគទ្រព្យដើម្បីសាងប្រទេសជាតិ ទានៈ ឲ្យទ្រព្យដល់បុគ្គលម្នាក់ៗ ខ្ញុំមិនស្របតាមមតិនេះទេ ។ តាមពិត បរិច្ចាគក្នុងទីនេះជ្រៅណាស់ សំដៅយកការលះបង់គំនុំគុំគួន ការលះសេចក្តីសុខផ្ទាល់ខ្លួន រហូតដល់ពេលខ្លះហ៊ានលះបង់ជីវិត ដើម្បីសេចក្តីសុខរបស់ប្រជារាស្ត្រ និង ប្រទេសជាតិ ។

៤-**អាជ្ជវៈ** សេចក្តីស្មោះត្រង់ មិនមានពុតត្បុត មិនធ្វើប្រជាភិថុតិ ។

៥-**មទ្ទវៈ** សុភាព ទន់ភ្លន់ ម៉ត់ចត់ល្អណាស់ គួរជាទីស្រឡាញ់ និងគោរពកោតខ្លាច ។

៦-**តបះ** អ្នកខ្លះគេថា បានដល់ការរក្សាឧបោសថ ឯសីលៈ គឺការកាន់ត្រឹមតែសីល ៥ ខ្ញុំមិនស្របតាមមតិនេះទេ ។ **តបះ** សំដៅយកការប្រព្រឹត្តិដុតកិលេស គឺហ្វឹកហាត់បដិបត្តិសមថៈ និងវិបស្សនាផង ដុតមនុស្សខូចឲ្យទទួលទណ្ឌកម្មតាមច្បាប់ផង ។ មិនធ្វើព្រងើយកន្តើយ ឬ ស៊ុំគ្រលុំ រកមុខមិនឃើញ និទណ្ឌភាពរហូតនោះទេ ។

៧-**អក្កោធះ** មិនក្រេវក្រោធ មានមេត្តាប្រចាំនៅក្នុងចិត្តពិចារណាកាត់សេចក្តី មិនឲ្យខុសខូចខាត ។

៨-**អវិហឹសា** មិនបៀតបៀន មានករុណាប្រចាំនៅក្នុងចិត្តមិនយកពន្ធដារហួសពេក ឬ មិនកេណ្ឌកម្លាំងជ្រុលពេកជាដើម ។

៩-ខន្តិ សេចក្តីអត់ធន់ តស៊ូគ្រប់ករណីយកិច្ចដែលត្រឹមត្រូវស្របច្បាប់ ។

១០-អវិរោធនៈ មានចិត្តរឹងមាំ មិនឃ្លាតចាកគន្លងធម៌ មិនឃ្លេងឃ្លោងតាមឥដ្ឋារម្មណ៍ ឬ អនិដ្ឋារម្មណ៍ ។

គប្បីចងចាំងាយៗ ភាសាបាលីដូចតទៅនេះ –

**ទានំ សីលំ បរិច្ចាគំ អាជ្ជវំ មទ្ទវំ តបំ**
**អក្កោធំ អវិហឹសញ្ច ខន្តិញ្ច អវិរោធនំ ។**

ធម៌ដែលព្រះរាជា ឬ អ្នកដឹកនាំត្រូវបដិបត្តិ នៅមានទៀតច្រើនណាស់ ប៉ុន្តែ ដើម្បីកុំឲ្យពេលវេលាវែងពេក អាត្មាភាព គ្រាន់តែ

បន្ថែមបន្តិចថា រឿងស្រីៗ ជារឿងធំ ត្រូវចាំកុំភ្លេច ស្រីៗពូកែណាស់ ចាមអស់ប្រទេសទាំងមូលព្រោះស្រីៗ ខ្មែរអស់ទឹកដីមួយចំនួនក៏ព្រោះស្រីៗដែរ អស់លោកស្រីៗមានមន្តអាគមន៍ខ្លាំងណាស់ ប្រយ័ត្ន... កុំមាត់ កុំត្រចៀកស្រាល ។

មុននឹងបញ្ចប់ធម៌ទេសនា ក្នុងនាមព្រះសង្ឃ គណៈកម្មការ និងពុទ្ធបរិស័ទវត្តពោធិវង្ស អាត្មាភាព សូមថ្វាយព្រះរាជកុសល និងថ្វាយព្រះពរជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការ ចំពោះ ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សូមព្រះអង្គមានព្រះសុខមាលភាពល្អ មានបញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិ ឆ្លងកាត់ទុក្ខលំបាកគ្រោះថ្នាក់ឧបសគ្គផ្សេងៗ ដល់ទីកន្លែងសុខចំរើនថ្កុំថ្កើងរុងរឿងឡើងវិញ និង សូមព្រះអង្គ មានព្រះជន្មាយុយឺនយូរ ស្ថិតនៅក្នុងរាជសម្បត្តិ ប្រកបដោយទសពិធរាជធម៌ ដឹកនាំប្រជានិករ បានជោគជ័យ សិរីសួស្តី ត្រជាក់ត្រជុំក្សេមក្សាន្ត កុំបីអាក់ខានឡើយ ។

ធម្មទេសនា និដ្ឋិតា

ព្រះធម៌ទេសនា ចប់ត្រឹមប៉ុណ្ណោះ ឯវំ ៕

# ធម្មិករាជសូត្រ

ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាមិនប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការ មិនប្រកបដោយធម៌ដែរ, ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការ មិនប្រកបដោយធម៌ សម័យនោះ ពួកព្រាហ្មណ៍ និង គហបតី ក៏មិនប្រកបដោយធម៌ដែរ, កាលពួកព្រាហ្មណ៍ និង គហបតី មិនប្រកបដោយធម៌ សម័យនោះ ពួកអ្នកនិគម និង អ្នកជនបទ ក៏មិនប្រកបដោយធម៌ដែរ, កាលពួកអ្នកនិគម និង អ្នកជនបទ មិនប្រកបដោយធម៌ ព្រះចន្ទ និង ព្រះអាទិត្យ ក៏គោចរទៅមិនស្មើដែរ, កាលព្រះចន្ទ និង ព្រះអាទិត្យ គោចរទៅមិនស្មើ ពួកផ្កាយនក្ខត្តឫក្ស គោចរទៅមិនស្មើដែរ កាលពួកផ្កាយនក្ខត្តឫក្ស គោចរទៅមិនស្មើ យប់ និង ថ្ងៃក៏ប្រព្រឹត្តទៅមិនស្មើដែរ, កាលយប់ និង ថ្ងៃប្រព្រឹត្តទៅមិនស្មើ ខែ និង កន្លះខែ ក៏ប្រព្រឹត្តទៅមិនស្មើដែរ, កាលខែ និង កន្លះខែប្រព្រឹត្តទៅមិនស្មើ រដូវ និងឆ្នាំក៏ប្រព្រឹត្តទៅមិនស្មើដែរ, កាលរដូវ និង ឆ្នាំប្រព្រឹត្តទៅមិនស្មើ ខ្យល់ក៏បក់មិនស្មើដែរ, កាលខ្យល់បក់មិនស្មើ ខ្យល់ប្រចាំរដូវ ក៏ប្រព្រឹត្តទៅមិនស្មើដែរ, កាលខ្យល់ប្រចាំរដូវ ប្រព្រឹត្តទៅមិនស្មើ ទេវតាទាំងឡាយ ក៏ខឹងសម្បា កាលទេវតាទាំងឡាយ ខឹងសម្បា ភ្លៀងក៏មិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ, កាលភ្លៀងមិនបង្អុរចុះមកដោយប្រពៃ ស្រូវទាំងឡាយ ក៏ឲ្យផលមិនស្មើល្អ (ទុំមិនពេញទឹក) ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស កាលបរិភោគ ស្រូវឲ្យផលមិនស្មើល្អ

រមែងមានអាយុខ្លី មានសម្បុរអាក្រក់ មានកម្លាំងតិច មានអាពាធច្រើន ។

ម្នាលភិក្ខុទាំងឡាយ សម័យណា ពួកព្រះរាជាប្រកបដោយធម៌ សម័យនោះ ពួកខ្ញុំរាជការ ក៏ប្រកបដោយធម៌ដែរ, ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការ ប្រកបដោយធម៌ សម័យនោះ ពួកព្រាហ្មណ៍ និង គហបតី ក៏ប្រកបដោយធម៌ដែរ, កាលពួកព្រាហ្មណ៍ និង គហបតី ប្រកបដោយធម៌ សម័យនោះ ពួកអ្នកនិគម និង អ្នកជនបទ ក៏ប្រកបដោយធម៌ដែរ, កាលពួកអ្នកនិគម និង អ្នកជនបទ ប្រកបដោយធម៌ ព្រះចន្ទ និង ព្រះអាទិត្យ ក៏គោចរទៅស្មើល្អ, កាលព្រះចន្ទ និង ព្រះអាទិត្យ គោចរទៅស្មើល្អ ពួកផ្កាយនក្ខត្តឫក្ស ក៏គោចរទៅស្មើល្អដែរ. កាលពួកផ្កាយនក្ខត្តឫក្ស គោចរទៅស្មើល្អ យប់ និងថ្ងៃ ក៏ប្រព្រឹត្តទៅស្មើល្អដែរ, កាលយប់ និង ថ្ងៃ ប្រព្រឹត្តទៅស្មើល្អ ខែ និង កន្លះខែ ក៏ប្រព្រឹត្តទៅស្មើល្អដែរ, កាលខែ និង កន្លះខែ ប្រព្រឹត្តទៅស្មើល្អ រដូវ និង ឆ្នាំ ក៏ប្រព្រឹត្តទៅស្មើល្អដែរ, កាលរដូវ និង ឆ្នាំ ប្រព្រឹត្តទៅស្មើល្អ ខ្យល់ក៏បក់ស្មើល្អដែរ, កាលខ្យល់បក់ស្មើល្អ ខ្យល់ប្រចាំរដូវ ក៏ប្រព្រឹត្តទៅស្មើល្អដែរ,កាលខ្យល់ប្រចាំរដូវ ប្រព្រឹត្តទៅស្មើល្អ ទេវតាទាំងឡាយ ក៏មិនខឹងសម្បា, កាលទេវតាទាំងឡាយ មិនខឹងសម្បា ភ្លៀងក៏បង្អុរទឹកភ្លៀងចុះមកដោយប្រពៃ, កាលភ្លៀង បង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវទាំងឡាយ ក៏ឲ្យផលស្មើល្អ,(ទុំពេញទឹក) ម្នាលភិក្ខុទាំងឡាយ ពួកមនុស្ស កាលបរិភោគស្រូវ

ឲ្យផលល្អើល្អ, រមែងមានអាយុវែង មានសម្បុរល្អ មានកម្លាំងខ្លាំងក្លា មានអាពាធតិច ។

គុន្នញ្ចេ តរមានានំ ជិម្ហំ គច្ឆតិ បុង្គវោ
សព្វា តា ជិម្ហំ គច្ឆន្តិ នេត្តេ ជិម្ហំ គតេ សតិ
ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេ អធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ ទុក្ខំ សេតិ រាជា ចេ ហោត្យធម្មិកោ ៕
គុន្នញ្ចេ តរមានានំ ឧជុំ គច្ឆតិ បុង្គវោ
សព្វា តា ឧជុំ គច្ឆន្តិ នេត្តេ ឧជុំ គតេ សតិ
ឯវមេវ មនុស្សេសុ យោ ហោតិ សេដ្ឋសម្មតោ
សោ ចេ ធម្មំ ចរតិ បគេវ ឥតរា បជា
សព្វំ រដ្ឋំ សុខំ សេតិ រាជា ចេ ហោតិ ធម្មិកោតិ ៕

កាលណាហ្វូងគោ ហែលឆ្លងកាត់ទឹក
បើមេហ្វូងដឹក នាំហែលខុសផ្លូវ
កូនហ្វូងដែលនាំ គ្នាហែលតាមទៅ
តែងហែលខុសផ្លូវ ទៅតាមតាមគ្នា ។
ដូចជាមនុស្ស នៅក្នុងសង្គម
បើលោកអ្នកធំ ដឹកនាំប្រជា

មិនគោរពច្បាប់ និងព្រះធម្មា
ពលរដ្ឋគ្រប់គ្នា តែងយកតម្រាប់ ។
ប្រទេសជាតិ និង ពួកប្រជាជន
ទុក្ខសោកធ្ងរធ្ងន់ សល់សែនឱនអាប់
វិនាសសាបសូន្យ យ៉ាងរហ័សឆាប់
ព្រោះដើរខុសច្បាប់ គ្រប់គ្រប់គ្នាទៅ ។
កាលណាហ្វូងគោ ហែលឆ្លងកាត់ទឹក
បើមេហ្វូងដឹក នាំហែលត្រូវផ្លូវ
កូនហ្វូងដែលនាំ គ្នាហែលតាមទៅ
តែងហែលត្រូវផ្លូវ ទៅតាមតាមគ្នា ។
ដូចជាមនុស្ស នៅក្នុងសង្គម
បើលោកអ្នកធំ ដឹកនាំប្រជា
គោរពតាមច្បាប់ និងព្រះធម្មា
ពលរដ្ឋគ្រប់គ្នា តែងយកតម្រាប់ ។
ប្រទេសជាតិ និង ពួកប្រជាជន
ចំរើនទ្រព្យធន និងកិត្តិស័ព្ទ
ថ្កុំថ្កើងរុងរឿង យ៉ាងរហ័សឆាប់
ព្រោះដើរត្រូវច្បាប់ គ្រប់គ្រប់គ្នាអឺយ(១) ៕

---

(១)-សុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ៤២/ ៧១/ ១៨៤

# គណ្ឌុតិណ្ឌុកជាតក

ព្រះសម្មាសម្ពុទ្ធ គង់នៅវត្តព្រះជេតពន បានត្រាស់សម្តែងព្រះធម្មទេសនា –

**អប្បមាទោ អមតំ បទំ  បមាទោ មច្ចុនោ បទំ**
**អប្បមត្តា ន មីយន្តិ  យេ បមត្តា យថា មតា ១**

។ល។

ក្នុងអតីតកាល ព្រះរាជាព្រះនាមបញ្ចាលៈ ក្នុងឧត្តរបញ្ចាលនគរ ដែនកបិលៈ ជាអ្នកប្រមាទគ្រប់គ្រងរាជសម្បត្តិ មិនប្រកបដោយធម៌ ។ នាម៉ឺនមុខមន្ត្រីរបស់ព្រះអង្គ ក៏មិនប្រកបដោយធម៌ ។ រាស្ត្រប្រជាកើតទុក្ខលំបាកក្តៅក្រហាយ ពេលថ្ងៃអ្នករាជការបៀតបៀន ពេលយប់ត្រូវចោរចូលលួចប្លន់... កើតអសន្តិសុខ ពេញផ្ទៃប្រទេស។

គ្រានោះ ព្រះពោធិសត្វ កើតជារុក្ខទេវតា អាស្រ័យនៅគណ្ឌុតិណ្ឌុកព្រឹក្ស ខាងក្រៅព្រះនគរ ។ រុក្ខទេវតា តែងបានទទួលពលីការជាច្រើនពីព្រះរាជា រៀងរាល់ឆ្នាំ ។ រុក្ខទេវតានោះ គិតថា ព្រះរាជាមានឧបការៈច្រើនដល់ខ្លួន ប៉ុន្តែ លោកជាអ្នកប្រមាទ គ្រប់គ្រងរាជសម្បត្តិ មិនប្រកបដោយធម៌ ប្រជាជនកើតទុក្ខក្តៅក្រហាយ ប្រទេសជាតិ នឹងវិនាសអន្តរាយ ជាមិនខាន... ក្រៅអំពីខ្លួនហើយ មិនមានបុគ្គលណាមួយ អាចរំលឹកដាស់តឿនព្រះរាជាអង្គនោះបានឡើយ ។ លុះគិតឃើញដូចនោះហើយ រុក្ខទេវតា ក៏ចូលទៅក្នុងក្រឡាព្រះបន្ទំរបស់ព្រះរាជា ហើយបញ្ចេញរស្មីដ៏ភ្លឺថ្លា ព្រះរាជាសួរថា

លោកជានរណា ? មកមានការអ្វី ? រុក្ខទេវតា ឆ្លើយថា ខ្ញុំជារុក្ខទេវតា មកដើម្បីនឹងថ្វាយឱវាទដល់ព្រះអង្គ ។

បពិត្រមហារាជ ព្រះអង្គ ជាអ្នកប្រមាទ គ្រប់គ្រងរាជសម្បត្តិមិនប្រកបដោយធម៌ ប្រទេសជាតិរបស់ព្រះអង្គ នឹងត្រូវវិនាសសាបសូន្យជាមិនខាន ។ ធម្មតា ព្រះរាជា អ្នកគ្រប់គ្រងដោយសេចក្តីប្រមាទ មិនឈ្មោះថាជាម្ចាស់របស់ប្រទេសជាតិក្នុងបច្ចុប្បន្ននេះទេ លុះស្លាប់ទៅរមែងទៅកើតក្នុងនរកទៀត ។ ម្យ៉ាងទៀត បើព្រះរាជាជាអ្នកប្រមាទហើយ អ្នកនៅក្នុងព្រះរាជសំណាក់ក្តី អ្នកនៅខាងក្រៅព្រះរាជសំណាក់ក្តី នឹងទៅជាអ្នកប្រមាទតាមគ្នាទាំងអស់ ព្រោះហេតុនោះ ព្រះអង្គមិនគប្បីជាអ្នកប្រមាទ គ្រប់គ្រងរាជសម្បត្តិឡើយ។ល។ បពិត្រមហារាជ សូមព្រះអង្គ ស្តេចត្រាច់ទៅតាមស្រុកតូចធំនិគមជនបទ ទ្រង់នឹងបានទតឃើញ បានទ្រង់ព្រះសណ្តាប់ នូវហេតុការណ៍ផ្សេងៗ ផ្ទាល់ព្រះអង្គ ហើយសូមព្រះអង្គ ទ្រង់បដិបត្តិ ដោយប្រពៃចុះ ។

ព្រះរាជា ទ្រង់ព្រះសណ្តាប់ឱវាទរបស់រុក្ខទេវតានោះហើយ ស្ទុតព្រះហឫទ័យ ស្អែកឡើងប្រគល់ឲ្យអាមាត្យមើលការរាជសម្បត្តិព្រះអង្គ ព្រមទាំងបុរោហិត ក្លែងភេទ ស្តេចចេញចាកព្រះនគរ តាមព្រះទ្វារខាងកើត យាងទៅអស់ផ្លូវប្រមាណ ១ យោជន៍ បានជួបនឹងបុរសចាស់ម្នាក់ អង្គុយជោះបន្លាក្បែរទ្វារផ្ទះរបស់ខ្លួន ជេរប្រទេចផ្តាសាព្រះរាជាថា សូមឲ្យព្រះចៅបញ្ចាលរាជ ត្រូវសរក្នុងសង្គ្រាម

សោយទុក្ខវេទនា ដូចជាអាត្មាអញ ដែលត្រូវបន្លាមុត កើតទុក្ខវេទនា ដូចនោះ ។

បុរោហិត ក៏និយាយឡើងថា អ្នកឯងជាមនុស្សចាស់ មានភ្នែកងងឹត មើលអ្វីឃើញមិនច្បាស់ មុតបន្លាដោយខ្លួនឯង ហេតុអ្វីក៏ឲ្យកំហុសទៅព្រះបាទព្រហ្មទត្តទៅវិញ(២) ។

បុរសចាស់ និយាយថា ខ្ញុំនិយាយមិនខុសទេ ព្រះរាជាមិនបានមើលថែរក្សារាស្ត្រឲ្យល្អទេ ពេលថ្ងៃ អ្នករាជការចូលមកបៀតបៀន ពេលយប់ ចោរចូលមកលួចប្លន់ ប្រជាជនភ័យខ្លាច ទើបយកបន្លាមកបិទបាំងផ្ទះរបស់ខ្លួន ពេលថ្ងៃរត់ពួនក្នុងព្រៃ ពេលយប់រាត្រីទើបចូលមកផ្ទះវិញ ហេតុនេះហើយ ដែលនាំឲ្យមានបន្លាមុតជើងខ្ញុំ ។

ព្រះរាជា បានទ្រង់ព្រះសណ្ដាប់ដូចនោះហើយ បានត្រាស់នឹងបុរោហិតថា ម្នាលអាចារ្យ បុរសចាស់នេះ ពោលត្រឹមត្រូវហើយ នេះជាកំហុសរបស់យើងហើយ យើងត្រូវត្រឡប់ទៅគ្រប់គ្រងប្រកបដោយធម៌ ។ បុរោហិត ក្រាបទូលថា មហាបពិត្រ កុំអាលត្រឡប់ យើងត្រូវទៅលបស្ដាប់តទៅមុខទៀត ។

ព្រះរាជា យាងទៅមុខបន្តិចទៀត បានជួបនឹងយាយចាស់កំសត់ម្នាក់ កំពុងបេះបន្លែ ចិញ្ចឹមកូនក្រមុំ២នាក់ ដេរប្រទេចផ្កាសា

---

(២)-ព្រះបាទព្រហ្មទត្ត គឺព្រះបាទបញ្ចាល

ព្រះរាជាថា –

កាលណាហ្ន៎ ព្រះបាទព្រហ្មទត្ត នឹងសុគតបាត់ទៅ... ។ ក្នុងផែនដី ព្រះបាទព្រហ្មទត្ត ស្រីក្រមុំរកប្តីមិនបានទាល់ចាស់ ។

បុរោហិត ពោលជំទាស់ឡើងថា យាយឯងមិនស្គាល់ហេតុផល ចេះតែនិយាយ ចេះតែថា ព្រះរាជាឯណា ដែលទៅរកប្តីសឹមកឲ្យកូនខ្លួន ។

យាយចាស់ និយាយឡើងថា ខ្ញុំមិនមែនចេះតែនិយាយ ចេះតែថាទេ ព្រះរាជា មិនបានមើលថែរក្សារាស្ត្រឲ្យល្អទេ ពេលថ្ងៃ អ្នករាជការ ចូលមកបៀតបៀន ពេលយប់ចោរចូលមកលួចប្លន់ ទាំងទារពន្ធដារក៏ច្រើន ប្រជាជនក្រលំបាក មិនងាយនឹងចិញ្ចឹមប្រពន្ធកូនទេ បើយ៉ាងនេះ តើស្រីៗនឹងមានប្តីមកពីណា ។

ព្រះរាជា និង បុរោហិត ស្តាប់ហើយយល់ថា យាយចាស់នេះនិយាយត្រូវមែន ទើបស្តេចធ្វើដំណើរទៅមុខទៀត បានជួបនឹងអ្នកស្រែកំពុងតែជេរប្រទេចផ្តាសាព្រះរាជាថា សូមឲ្យព្រះបាទបញ្ចាលៈត្រូវដាវលំពែង ដួលដេកក្នុងសង្គ្រាម ដូចជាគោសាលិយៈ ត្រូវផាលដួលដេកដូចនោះ ។

បុរោហិត ពោលឡើងថា អ្នកឯងអីក៏អាក្រក់ម្លេះ អ្នកធ្វើឲ្យគោមុតផាល ដោយខ្លួនឯង ហេតុអ្វីក៏ទៅជេរព្រះបាទព្រហ្មទត្ត ។

អ្នកស្រែ និយាយឡើងថា ព្រះរាជា មិនបានគ្រប់គ្រងរាស្ត្រឲ្យល្អទេ ពេលថ្ងៃ អ្នករាជការចូលមកបៀតបៀន ពេលយប់ ចោរ

ចូលមកលួចប្លន់ អ្នកដាំបាយ ប្រហែលជាដាំបាយសាជាថ្មីទៀត បាន ជាយកបាយមកយឺតយូរខុសពេលវេលា ខ្ញុំរវល់តែសម្លឹងមើលផ្លូវអ្នកដាំ បាយ បានជាធ្វើឲ្យគោមុតផាល ។

ព្រះរាជា និង បុរោហិត ស្ដេចធ្វើដំណើរទៅមុខទៀត បានជួប នឹងអ្នករីតទឹកដោះគោ ត្រូវមេគោធាក់ដួល កំពប់ទឹកដោះគោអស់ ក្រោកឡើងជេរព្រះរាជា សូមឲ្យព្រះបាទបញ្ចាលរាជ ត្រូវគេកាប់ ដោយដាវក្នុងសង្គ្រាម ក្ដៅក្រហាយដូចជាអញ ត្រូវមេគោធាក់ដួល ដូចនោះ ។

បុរោហិត ពោលឡើងថា ការដែលមេគោធាក់អ្នកឯងដួលឈឺ ធ្វើឲ្យទឹកដោះគោកំពប់ តើវាជាកំហុសអីរបស់ព្រះបាទព្រហ្មទត្ត បាន ជាអ្នកឯងទិតៀនលោក ។

អ្នករីតទឹកដោះគោ ឆ្លើយថា ព្រះបាទបញ្ចាល ត្រូវតែគេ ទិតៀន ព្រោះព្រះអង្គ គ្រប់គ្រងមិនល្អ អ្នករាជការបៀតបៀនរាស្ត្រ កើតចោរលួចប្លន់ពេញប្រទេស មេគោកាចនេះ ពីដើមមក យើងខ្ញុំ មិនដែលរីតទឹកដោះវាទេ ថ្ងៃនេះ រាជបុរស ប្រើឲ្យយើងខ្ញុំ រីតទឹក ដោះវា បានជាវាធាក់យើងខ្ញុំដួលឈឺយ៉ាងនេះ ។

ព្រះរាជា និង បុរោហិត គិតថា អ្នកនេះ និយាយត្រូវ ទើប ស្ដេចធ្វើដំណើរឆ្ពោះមកកាន់ព្រះនគរវិញ បានជួបនឹងពួកក្មេងៗអ្នក ស្រុក កំពុងតែជេរព្រះរាជាថា សូមឲ្យព្រះបាទបញ្ចាលរាជ ព្រាត់ ប្រាសចាកព្រះរាជឱរស យំសោកខ្សឹកខ្សួល ដូចជាមេគោកំព្រាចាកកូន

រត់យំសោកខ្សឹកខ្សួលដូចនោះ ។

បុរោហិត ពោលថា ការដែលមេគោរបស់អ្នកឯង រត់យំសោកខ្សឹកខ្សួល ហេតុអីក៏ទៅជាកំហុសរបស់ព្រះរាជា បានជាអ្នកឯងជេរលោក ។

ក្មេងអ្នកស្រុក និយាយថា ព្រះរាជាគ្រប់គ្រងមិនល្អ ពេលថ្ងៃអ្នករាជការបៀតបៀនរាស្ត្រ ពេលយប់ចោរចូលលួចប្លន់ កូនគោរបស់យើងខ្ញុំ កំពុងតែបៅដោះ ត្រូវគេយកទៅសម្លាប់ ដើម្បីធ្វើស្រោមដាវនេះ មិនជាកំហុសរបស់ព្រះរាជាឬ ? ។

ព្រះរាជា និង បុរោហិត និយាយថា ល្អហើយ ពួកអ្នកឯងនិយាយមានហេតុមានផល ហើយក៏ជៀសចេញទៅ ជួបនឹងស្រះគោករីងមួយកន្លែង ពួកកង្កែបទាំងឡាយ ជេរព្រះរាជាថា សូមឲ្យព្រះបាទបញ្ចាលរាជ ព្រមទាំងព្រះរាជឱរស ត្រូវគេប្រហារក្នុងសមរភូមិ ត្រូវហ្វូងក្អែកចោមចឹកស៊ី ដូចជាពួកយើងកើតក្នុងព្រៃ ត្រូវហ្វូងក្អែកអ្នកស្រុកចឹកស៊ីក្នុងថ្ងៃនេះ ដូចនោះ ។

បុរោហិត ឮហើយ បាននិយាយនឹងពួកកង្កែបនោះថា នែវ៉ើយកង្កែប ព្រះរាជា ក្នុងមនុស្សលោក នឹងចាត់ការថែរក្សាសត្វទូទៅមិនបានទេ ព្រះរាជា មិនមែនជាអធម្មចារីបុគ្គល ដោយហេតុត្រឹមតែហ្វូងក្អែកចឹកស៊ីសត្វរស់ ដូចជាពួកអ្នកប៉ុណ្ណោះទេ ។

កង្កែប ស្តាប់ហើយ ពោលថា លោក ជាព្រហ្មចារីជាតិអធម៌ទើបពោលសរសើរស្តេចបាន កាលបើប្រជាជនជាច្រើន កំពុងត្រូវគេ

ប្អូន អ្នកឯងនៅតែបួជាស្តេច ដែលគួរទិតៀនដូចនេះបានទៀត ។ ម្នាលព្រាហ្មណ៍ កាលបើផែនដីនេះ មានព្រះរាជាល្អហើយ ស្រុកទេស នឹងសម្បូណ៌សប្បាយ ពួកក្អែកទាំងឡាយ ក៏នឹងបានដុំបាយស៊ីល្អៗ ដែលជាពលី មិនចាំបាច់មកស៊ីសត្វរស់ ដូចជាពួកយើងនេះទេ។

ព្រះរាជា និង បុរោហិត ស្តាប់ពាក្យនោះហើយ ត្រិះរិះគិតថា ជនទាំងឡាយ ទាំងពួង សូម្បីតែសត្វក្អែបជាសត្វតិរច្ឆានក្នុងព្រៃ ក៏នាំគ្នាជេរប្រទេចយើងតែម្នាក់ឯងប៉ុណ្ណោះ ហើយក៏ស្តេចចេញចាកទីនោះ ចូលកាន់ព្រះនគរ សោយរាជសម្បត្តិ គ្រប់គ្រងដោយធម៌ តាំងនៅក្នុងឱវាទរបស់រុក្ខទេវតាព្រះពោធិសត្វ សាងបុណ្យកុសល សីល ទាន រៀងដរាបតទៅ ។

ព្រះសាស្តា នាំធម្មទេសនា មកសម្តែងដល់ព្រះបាទកោសល ហើយត្រាស់ថា មហាបពិត្រ ធម្មតា ព្រះរាជា ត្រូវលះ អគតិធម៌ ហើយសោយរាជ្យប្រកបដោយធម៌ ។ ព្រះអង្គ ប្រជុំជាតក ថា ភណ្ឌុតិណ្ឌុកទេវតា ក្នុងកាលនោះ បានមកជាតថាគត ក្នុងកាលឥឡូវនេះឯង (៣) ៕

---

(៣)-សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ៦០/៥៤៨/២១៥

# ចក្កវត្តិសូត្រ

ក្នុងចក្កវត្តិសូត្រ មាននិយាយអំពីស្តេចចក្រពត្តិ ។ ស្តេចចក្រពត្តិ ដែលយើងតែងនិយាយគ្នាសព្វថ្ងៃ សំដៅយកស្តេច ឬប្រទេសណា ដែលដើរឈ្លានពាន ជិះជាន់ សង្កត់សង្កិន បៀតបៀនគេ... ។ ប៉ុន្តែ ស្តេចចក្រពត្តិ ក្នុងគម្ពីរព្រះត្រៃបិដក ក្នុងចក្កវត្តិសូត្រ សំដៅយកស្តេចប្រកបដោយធម៌ ជាស្តេចល្អ ស្តេចមានបុណ្យបារមី គួរគោរពបូជា ផ្ទុយគ្នាស្រឡះពីពាក្យដែលយើងធ្លាប់តែនិយាយ ។ ស្តេចចក្រពត្តិ សម្បូណ៌ដោយកែវ ៧ ប្រការគឺ :-

| | |
|---|---|
| ១-ចក្ករតន៍ | ចក្រកែវ |
| ២-ហត្ថីរតន៍ | ដំរីកែវ |
| ៣-អស្សរតន៍ | សេះកែវ |
| ៤-មណិរតន៍ | កែវមណី |
| ៥-ឥត្ថីរតន៍ | ស្រីកែវ |
| ៦-គហបតិរតន៍ | គហបតីកែវ |
| ៧-បរិនាយករតន៍ | នាយពលកែវ |

កែវ ៧ ប្រការនេះ ជាពិសេស ចក្រកែវដ៏ជាទិព្វ តែងកើតឡើងដោយបុណ្យបារមីរបស់ស្តេចចក្រពត្តិ ។ បើស្តេចអង្គណាបដិបត្តិតាម ចក្កវត្តិវត្ត បានត្រឹមត្រូវល្អគ្រប់គ្រាន់ហើយ ចក្រកែវដ៏ជាទិព្វនោះ នឹងកើតឡើង ។

# ចក្កវត្តិវត្ត

ចក្កវត្តិវត្ត ឧបដិបត្តិរបស់ស្ដេចចក្រពត្តិ ។ ឧបដិបត្តិរបស់ស្ដេចចក្រពត្តិ ក្នុងគម្ពីរព្រះត្រៃបិដក លោកនិយាយជាទូទៅ មិនបានរៀបរាប់ជាខៗទេ ប៉ុន្តែ ខ្ញុំប្រមូលជាខៗ ដើម្បីងាយចំណាំ មាន ៥ ប្រការ ដូចតទៅនេះ : -

១-**ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ មានេន្តោ ធម្មំ បូជេន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ** សក្ការៈធម៌ គោរពធម៌ រាប់អានធម៌ បូជាធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាកំពូល យកធម៌ជាអធិបតី ។

២-**ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហស្សុ អន្តោជនស្មឹ ពលកាយស្មឹ ខត្តិយេសុ អនុយន្តេសុ ព្រាហ្មណគហបតិកេសុ នេគមជានបទេសុ សមណព្រាហ្មណេសុ មិគបក្ខីសុ** ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌ ចំពោះជនខាងក្នុងគឺបុត្រ ភរិយា ចំពោះពួកពល ពួកក្សត្រ ពួកជនចុះចូល ពួកព្រាហ្មណ៍ គហបតី ពួកអ្នកនិគមអ្នកជនបទ ពួកសមណព្រាហ្មណ៍ ពួកម្រឹគបក្សី ។

៣-**អធម្មការោ បវត្តិត្ថ** កុំឲ្យមានអំពើអធម៌ នៅក្នុងប្រទេស ។

៤-**យេ តេ អធនា តេសញ្ច ធនំ អនុប្បទេយ្យាសិ** ត្រូវផ្ដល់ទ្រព្យឲ្យដល់ជនអ្នកក្រីក្រ ។

**៥-យេ តេ សមណព្រាហ្មណា មទប្បមាទា បដិវិរតា ខន្តិសោរច្ចេ និវិដ្ឋា... កឹ កុសលំ កឹ សាវជ្ជំ កឹ អនវជ្ជំ កឹ សេវិតព្វំ កឹ ន សេវិតព្វំ កឹ មេ ករិមានំ ទីឃរត្តំ អហិតាយ ទុក្ខាយ អស្ស កឹ វា បន មេ ករិមានំ ទីឃរត្តំ ហិតាយ សុខាយ អស្ស...** គប្បីចូលទៅរកសមណព្រាហ្មណ៍ អ្នកវៀរចាកសេចក្តីស្រវឹង និង សេចក្តីប្រមាទ តាំងនៅក្នុងខន្តិ និង សោរច្ចៈ ហើយសាកសួរថា អ្វីជាកុសល អ្វីជាអកុសល អ្វីជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព អំពើដូចម្តេចដែលខ្ញុំធ្វើទៅហើយ មិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែង មួយទៀត អំពើដូចម្តេចដែលខ្ញុំធ្វើទៅហើយ ជាប្រយោជន៍ ជាសុខអស់កាលយូរអង្វែង លុះបានស្តាប់ពាក្យសមណព្រាហ្មណ៍នោះហើយ គប្បីវៀរនូវអំពើដែលជាអកុសល ហើយសមាទានប្រព្រឹត្តនូវអំពើដែលជាកុសល នេះឯងជាវត្តដ៏ប្រសើរ របស់ស្តេចចក្រពត្តិ ។

ក្នុងចក្កវត្តិវត្ត ៥ ប្រការនោះ អ្នកខ្លះគេបំព្រួញនៅខ្លីត្រឹម ៣ ប្រការគឺ ប្រការ ១ ប្រការ ២ ប្រការ ៣ គេបញ្ចូលគ្នាតែ ១ ប្រការប៉ុណ្ណោះ ។ ចំណែកក្នុងអដ្ឋកថា លោកចែក ចក្កវត្តិវត្ត ជា ១០ ប្រការគឺ យកប្រការទី ២ មកចែកជា ៧ ប្រការគឺ

១-ពួកទាហាន ជាជនខាងក្នុង

២-ពួកក្សត្រ

៣-ក្សត្រប្រទេសរាជ (ពួកចុះចូល)

៤-ពួកព្រាហ្មណ៍ និង គហបតី

៥-ពួកអ្នកនិគម និង ជនបទ

៦-ពួកសមណព្រាហ្មណ៍

៧-ពួកម្រឹគ និង បក្សី

៨-មិនធ្វើអំពើអធម៌

៩-ចែកទ្រព្យឲ្យអ្នកក្រីក្រ

១០-សាកសួរបញ្ហា អ្វី ជាកុសល អ្វី ជាអកុសល ... ។

បើចែក ព្រាហ្មណ៍ ១ គហបតី ១ ម្រឹក ១ បក្សី ១ នឹងទៅចក្កវត្តិវត្ត មាន ១២ ប្រការ ។ ឯប្រការទី ១ លោកបញ្ចូលក្នុងប្រការទី ៨ ។

ការចែកវត្តរបស់ស្តេចចក្រពត្តិ តិច ឬ ច្រើនប្រការ ស្រេចនៅលើអធ្យាស្រ័យចុះ មិនមានអ្វីទាស់ខុសទេ ប្រការសំខាន់ នៅលើការយកចិត្តទុកដាក់បដិបត្តិតាម ។ បើគេបដិបត្តិតាមបានដូចនេះ សូម្បីចក្រកែវដ៏ជាទិព្វ មិនកើតឡើងក៏ដោយ សង្ឃឹមថា ស្រុកទេសនឹងបានសុខសប្បាយ ចំរើនរុងរឿង ជាពុំខាន (៤) ។

---

(៤)-សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ ១៨ / ៣៣ /១១៥

# ភាគកំណាព្យ

## ព្រហ្មវិហារធម៌

ព្រហ្មវិហារធម៌ ៤ ប្រការ  ១គឺមេត្តាក្តីរាប់អាន
២ករុណាណិតចិត្តសន្តាន  ជួយឲ្យគេបានរួចចាកទុក្ខ ។
៣ គឺមុទិតាចិត្តទន់  រីករាយអនន្តមិនបើសមុខ
ពេលឃើញគេបានសេចក្តីសុខ  សប្បាយរីកមុខឥតឫស្យា ។
៤ ឧបេក្ខាចិត្តកណ្តាល  ស្មោះត្រង់ត្រកាលគ្រប់រូបា
ឥតមានលំអៀងទៅខាងណា  ដើរតាមធម៌អាថ៌ជាបន្ទាត់ ។
ធម៌ ៤ យ៉ាងនេះរបស់ព្រហ្ម  ឬអ្នកដឹកនាំបដិបត្តិ
អ្នកឋានៈធំពិតប្រាកដ  ក៏ត្រូវបដិបត្តិដូចគ្នាដែរ ។
បើបដិបត្តិត្រឹមត្រូវហើយ  ទុក្ខសោកក៏ស្បើយសុខឥតល្ហែ
សប្បាយរីករាយរាល់ថ្ងៃខែ  ជនរួមជាតិខ្មែរថ្កើងឡើងវិញ ។
ដូចនេះត្រូវនាំគ្នាសិក្សា  រៀនធម៌រៀនអាថ៌ខំទន្ទេញ
កាន់ព្រហ្មវិហារឲ្យពោរពេញ  ជាតិបានចំណេញសុខសាន្តអើយ

## អគតិធម៌

អគតិធម៌ ៤ ប្រការ  ១គឺឆន្ទាគតិចិត្ត
លំអៀងព្រោះស្រឡាញ់គេពិត  បានដឹកនាំចិត្តឲ្យធ្វើខុស ។

២គឺទោសាគតិផ្ទៀង ប្រព្រឹត្តលំអៀងព្រោះស្អប់នោះ
បានជានាំចិត្តធ្វើដូចនោះ កើតជាកំហុសព្រោះទោសៈ ។
៣គឺមោហាគតិធម៌ វង្វេងត្រាច់ចរដូចគេខ្វាក់
លំអៀងព្រោះមិនបានដឹងជាក់ នាំឲ្យគ្រោះថ្នាក់ដល់អ្នកផង ។
៤គឺភយាគតិពិត ព្រោះតែភ័យភិតចិត្តសៅហ្មង
បានជាលំអៀងចាកច្បាប់ផង និងខុសគន្លងព្រះធម្មា ។
បើដើរតាមអគតិធម៌ មិនភ្លឺស្វាងល្អមិនសុខជា
ទ្រង់ត្រាស់ប្រៀបដូចព្រះចន្ទ្រា ដែលស្ថិតនៅនាខាងរនោច ។
បើគេវៀរអគតិធម៌ សុខចំរើនល្អលែងហិនហោច
រីងរឹតតែភ្លឺស្វាងរុងរោចន៍ ទ្រង់ប្រៀបប្រដូចចន្ទខាងខ្នើត ។
ដូចនេះបងប្អូនខ្មែរទាំងឡាយ បើចង់សប្បាយថ្ងៃថ្នាដើត
ដូចជាព្រះចន្ទនៅខាងខ្នើត លះកុំឲ្យកើតអគតិធម៌ ៕

## សង្គហធម៌

សង្គហធម៌ ៤ ប្រការ ១ទានៈការដាក់ទានឲ្យ
នូវទ្រព្យរបស់អ្វីក៏ដោយ ឬមួយក៏ឲ្យនូវវិជ្ជា ។
២បិយវាចាពាក្យសំដី ពិរោះឥតបីនឹងពណ៌នា
គេចូលចិត្តស្ដាប់គ្រប់ៗគ្នា ព្រោះមានខ្លឹមសារសំខាន់ណាស់ ។

ពាអត្ថចរិយាការប្រព្រឹត្តិ ជាប្រយោជន៍ពិតឃើញជាក់ច្បាស់
ជួយធ្វើកិច្ចការនៃក្មេងចាស់ ប្រឹងខិតខំណាស់សីលធម៌ ។
៤សមានត្តតាការទុកដាក់ ខ្លួននៅក្នុងថ្នាក់ដ៏បវរ
មិនខ្ពស់មិនទាបសមរម្យល្អ ទោះជនណាក៏រាប់អានបាន ។
បើគិតសង្គ្រោះអ្នកដទៃ ចូរខំលកលៃកុំបីខាន
យកសង្គហៈជាលំអាន នោះអ្នកនឹងបានជោគជ័យល្អ ។
បើអ្នកគិតរកតែអំណោយ ដើម្បីចែកឲ្យអ្នកក្រីក្រ
តែអ្នកប្រព្រឹត្តមិនសូវល្អ ទោះយ៉ាងណាក៏គ្មានជោគជ័យ ។
ហេតុនេះអស់លោកអ្នកសង្គ្រោះ ទាំងស្រីទាំងប្រុសត្រូវរំពៃ
ធ្វើតាមសង្គហធម៌ថ្លាថ្លៃ នឹងបានជោគជ័យបរិបូណ៌ហោង៕

## រាជសង្គហធម៌

រាជសង្គហធម៌ ៤ ប្រការ សំរាប់រាជាដ៏ជាធំ
និងអស់លោកអ្នកថ្នាក់ដឹកនាំ ត្រូវតែខិតខំរៀនឲ្យចាំ ។
១សស្សមេធៈចែកពូជស្រូវ ឬចែកឲ្យនូវពូជដំណាំ
ដល់កសិករអ្នកដុះដាំ ធ្វើការប្រចាំស្រែចំការ ។
ជួយរកវិធីបង្កើនផល ដើម្បីនឹងផ្តល់គេផងណា
បើគេបានផលច្រើនអស្ចារ្យ នឹងជួយរដ្ឋាឲ្យវឌ្ឍនា ។

២បុរិសមេធៈឆ្លៀវឆ្លាតក្នុង ទំនុកបំរុងអ្នករាជការ
ទាហានស៊ីវិលទាំងអស់គ្នា ឲ្យបានសុខាសមរម្យផង ។
ជួយមនុស្សល្អ និង ពូកែ ឲ្យរឹងរឹតតែល្បីចម្បង
បញ្ចេញស្នាដៃសាងជាតិផង ឲ្យច្រើនកន្ទងល្អប្រពៃ ។
៣សម្មាបាសៈអន្ទាក់ល្អ ជួយអ្នកក្រីក្រអ្នកកែច្នៃ
ចង់បង្កើតមុខរបរអ្វី មានទ្រព្យឲ្យខ្ចីធ្វើដើមទុន ។
៤រាជបេយ្យៈពាក្យពិរោះ មានខ្លឹមសារខ្ពស់កបដោយគុណ
មានផលប្រយោជន៍ច្រើនអនន្ត ស្តាប់មិនឆ្អែតឆ្អន់ចង់ស្តាប់ទៀត ។
បើអ្នកដឹកនាំធ្វើដូចនេះ គេទុកជាចេះមិនចោលម្សៀត
គេទុកជូនលោកដឹកនាំជាតិ បន្តទៅទៀតអង្វែងទៅ ។
បើធ្វើមិនបានកុំមុខក្រាស់ ខំក្រាញខ្លាំងណាស់ចង់តែនៅ
ចុះទៅឲ្យបាត់ស្រមោលទៅ កុំចង់ស្ថិតនៅខ្មាសកង្កែប ។
និយាយប៉ុណ្ណេះត្រូវចេះស្តាប់ បញ្ចប់សាសព្ទដោយសង្ខេប
បើចង់ដឹងរឿងសត្វកង្កែប ដើរស្តាប់អែបៗគង់តែដឹង ៕

៚✲៛

## នាយកធម៌

នាយកធម៌ ៦ ប្រការ ទី ១ ខមាការអត់ធន់
ទោះក្តៅត្រជាក់ស្រាលឬធ្ងន់ មិនដែលទម្រន់ស្ងួជានិច្ច ។

២ជាគរិយៈភ្ញាក់រលឹក ពេលយប់ពេលព្រឹកមិនដែលភ្លេច
ការងារដែលជាករណីយកិច្ច ប្រយ័ត្នជានិច្ចឥតចន្លោះ ។
៣ឧដ្ឋានៈ ការប្រឹងប្រែង ខ្មីឃ្មាតស្វះស្វែងគ្រប់ទាំងអស់
ធ្វើកិច្ចការអ្វីឥតមានខ្ចោះ កើតបានទាំងអស់ព្រោះឧស្សាហ៍ ។
៤សំវិភាគការបែងចែក ភោគផលចំណែកគ្រប់រូបា
ដើម្បីគេបានបរិភោគ្គា និងបានសុខារីករាយផង ។
៥គឺទយាក្តីអាណិត អាសូរគេពិតពេកកន្លង
តែងជួយឲ្យគេរួចទុក្ខផង មិនដែលមួហ្មងបៀតបៀនឡើយ ។
៦ឥក្ខណា ការរំពៃ មើលខុសត្រូវអ្វីឥតកន្តើយ
ត្រិះរិះម៉ត់ចត់ប្រាកដហើយ មិនធ្វើតោះតើយដោយប្រមាទ ។
លោកអ្នកដឹកនាំសក្តិសមល្អ រៀងនាយកធម៌លោកសង្វាត
ឬប្រឹងធ្វើតាមមិនខ្វះខាត ដើម្បីសុខស្អាតគ្រប់ៗគ្នា ៕

## អបរិហានិយធម៌

អបរិហានិយធម៌ ៧ ប្រការ ១គឺឧស្សាហ៍ប្រជុំគ្នា
ដើម្បីសម្រេចកិច្ចនានា ត្រូវប្រជុំគ្នាសួរយោបល់ ។
កុំធ្វើអ្វីអត្តនោម័តិ ក្រែងមានវិបត្តិអកុសល
ជាហេតុដែលនាំមកនូវផល ទុក្ខភ័យធ្លាក់ដល់យើងរាល់គ្នា ។

២ពេលប្រជុំត្រូវព្រមព្រៀង ធ្វើការឲ្យទៀងតាមវេលា
កុំទម្លាប់ធ្វើការខ្ជីខ្ជា មិនត្រូវវេលាដែលកំណត់ ។
ពេលឈប់ប្រជុំត្រូវព្រមព្រៀង ធ្វើការឲ្យទៀងតាមសន្មត
កុំចេញមុនគេគ្មានបែបបទ ធ្វើឲ្យម៉ត់ចត់ហើយស្រេចបាច់ ។
នឹងត្រូវព្រមព្រៀងធ្វើកិច្ចការ ដែលយើងរួមគ្នាបានសម្រេច
ត្រូវរួមគ្នាធ្វើឲ្យហើយស្រេច ទៅតាមសម្រេចយ៉ាងរហ័ស ។
៣មិនបញ្ញត្តច្បាប់ឡើងថ្មី ឬមិនឃ្លាតខ្ចីលុបច្បាប់ចាស់
ដើម្បីផលប្រយោជន៍ខ្លួនច្បាស់ ផលរាស្ត្រច្រើនណាស់ទៅជាខូច ។
ត្រូវតែរក្សាច្បាប់ដែលមាន ទុកជាប្រធានទាំងធំតូច
ព្រោះអីច្បាប់នោះមិនមានខូច ផលរាស្ត្រធំតូចណាទាំងអស់ ។
បើធ្វើច្បាប់ថ្មីឬលុបចាស់ ផលល្អច្រើនណាស់ទុកជាស្រេស
បានដល់រដ្ឋរាស្ត្រសព្វទាំងអស់ ធ្វើឬលុបចុះមិនទាស់អ្វី ។
៤ត្រូវគោរពលោកចាស់ទុំ នៅក្នុងសង្គមទាំងប្រុសស្រី
បើលោកឲ្យនូវយោបល់អ្វី គោរពសំដីលោកនោះផង ។
៥ត្រូវគោរពកុលស្ត្រី និងកុមារីកុំកន្ទង
រំលោភប្រពៃណីគេផង ដោយក្តីប៉ុនប៉ងចង់សប្បាយ ។
៦ត្រូវគោរពបូជា ចេតិយនានាផងទាំងឡាយ
កុំទៅកាប់គាស់បើកកាយ ធ្វើឲ្យប្រែក្លាយវិនាសបង់ ។
ទាំងផលប្រយោជន៍នៃចេតិយ ដែលជនប្រុសស្រីគេថ្វាយសង្ឃ
កុំទៅប៉ះពាល់ឲ្យបាត់បង់ ត្រូវទុកថ្វាយសង្ឃលោកចាត់ការ ។

៧ត្រូវតែខំគោរព ថែរក្សាគ្រប់អរហន្តា
ព្រមទាំងព្រះសង្ឃសាវកា ឲ្យគង់សុខាតរៀងទៅ ។
បើមិនទាន់មកសូមឲ្យមក បើលោកលែលកចង់គង់នៅ
ស្រេចតែព្រះអង្គសម្រេចទៅ សុខចិត្តគង់នៅយើងត្រេកអរ ។
ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា បើរដ្ឋឯណាប្រព្រឹត្តធម៌
៧ប្រការឲ្យបានល្អ មង្គលបវរនឹងកើតមាន ។
បើបរទេសចិត្តអាក្រក់ ចូលមកលួចឆក់ឬឈ្លានពាន
មិនអាចសម្រេចបំណងបាន ព្រោះរដ្ឋនោះមានសាមគ្គីល្អ ។
ហេតុនេះលោកអ្នកដឹកនាំខ្មែរ ចូរនាំគ្នាប្រែប្រព្រឹត្តធម៌
ឲ្យបានត្រឹមត្រូវដោយស្មោះសរ ខ្មែរសុខសាន្តល្អតរៀងទៅ ៕

ᨀ❋ᨁ

# ទសពិធរាជធម៌

ទសពិធរាជធម៌ ១០ ប្រការ ១ទានៈការចែកទានដល់
ជនអ្នកក្រីក្រជាបុគ្គល ឬមួយក៏ផ្ដល់ជាសាធារណ៍ ។
សាងប្រយោជន៍រួមក្នុងសង្គម ឲ្យបានសុខជុំរមនា
រីករាយសប្បាយទាំងអស់គ្នា សាងកម្ពុជាល្អថ្លៃថ្លា ។
២គឺសីលៈរក្សាសីល ជម្រះមន្ទិលកាយវាចា
កាន់៥ជានិច្ចរាល់វេលា ហើយថែមរក្សា៨ផង ។

៣គឺបរិច្ចាគលះគំនុំ　　មិនទុកឲ្យរុំចិត្តសៅហ្មង
លះទាំងក្តីសុខផ្ទាល់ខ្លួនផង　　ជីវិតកន្ទងហ៊ានលះដែរ ។
ដើម្បីក្តីសុខប្រជាជន　　នៅគ្រប់តំបន់ទឹកដីខ្មែរ
ស៊ូប្តូរជីវិតដោយក្តីស្នេហ៍　　ខំរក្សាថែកេរដូនតា ។
៤អាជ្ជវៈស្មោះត្រង់ពិត　　ឥតមានគំនិតវៀចតិចណា
ចំពោះបុគ្គលឬរដ្ឋា　　ឥតមានប្រជាភិថុតិឡើយ ។
៥មទ្ទវៈ ឫកសុភាព　　ទន់ភ្លន់ផរាបមិនចេះងើយ
ការងាររឹងប៉ឹងម៉ត់ចត់ហើយ　　មិនដែលកន្តើយម្តងណាសោះ ។
៦តបៈ ដុតកិលេស　　ដែលនៅសល់សេសឲ្យឆេះអស់
ឿ្វតខំធ្វើធម៌ឲ្យបានខ្ពស់　　ដើរតម្រង់ឆ្ពោះវិបស្សនា ។
និងដុតពួកជនដែលខិលខូច　　ដើរឆក់ប្លន់លួចទ្រព្យនានា
នាម៉ឺនទុច្ចរិតក៏ដូចគ្នា　　ត្រូវដុតពួកវាជាប្រញាប់ ។
កុំឲ្យមាននិទណ្ឌភាព　　រួចខ្លួនផរាបនៅលើច្បាប់
ត្រូវរកឲ្យឃើញហើយចងចាប់　　ដាក់វាក្រោមច្បាប់យ៉ាងតឹងរ៉ឹង ។
ទី ៧ គឺអក្កោធៈ　　ចិត្តមិនថ្នាំងថ្នាក់មិនក្រោធខឹង
មិនសម្រេចចិត្តតាមបណ្តឹង　　ត្រូវតែថ្លែងថ្លឹងរកការពិត ។
មិនដែលសៅហ្មងឬខូចការ　　ព្រោះមានមេត្តាប្រចាំចិត្ត
ធ្វើអ្វីតែងមានក្តីអាណិត　　អាសូរគេពិតចង់ឲ្យសុខ ។
៨គឺអវិហឹសា　　មានករុណាជួយដោះទុក្ខ
មិនដែលបៀតបៀនមិនបុករុក　　ធ្វើបាបអ្នកស្រុកដោយរឿងអ្វី ។

មិនកេណ្ឌកម្លាំងឬយកពន្ធ ដារជាទម្ងន់ទៅលើដី
ឬទៅលើមុខរបរអ្វី តែងមានប្រណីរាស្ត្រប្រជា ។
៩ខន្តីក្តីអត់ធន់ ទោះស្រាលឬធ្ងន់គ្រប់ការងារ
តស៊ូជានិច្ចមិនរួញរា គ្រប់ពេលវេលាការស្របច្បាប់ ។
១០គឺអវិរោធនៈ ចិត្តរឹងមាំជាក់មិនឡើងឆាប់
ឬចុះមកវិញជាប្រញាប់ អារម្មណ៍ប៉ះប៉ាប់ឃ្វេងឃ្វាងឡើយ។
មិនដែលប្រព្រឹត្តល្មើសច្បាប់ផង មិនឃ្លាតគន្លងធម៌ជាត្រើយ
បើធ្វើយ៉ាងនេះត្រឹមត្រូវហើយ រាស្ត្រនឹងបានស្បើយទុក្ខពុំខាន ។
ស្តេចឬអស់លោកអ្នកដឹកនាំ ត្រូវតែខិតខំធ្វើឲ្យបាន
នូវធម៌១០យ៉ាង យ៉ាងចំណាន ជាតិយើងថ្កើនថ្កានសុខសាន្តអឺយ៕

១៤ មេសា ២០០៥

ஐ❋ஐ

# កំណាព្យឆ្នាំចាស់

## ចំរើនពរអ្នកដឹកនាំ

សូមចំរើនពរអ្នកដឹកនាំ ទាំងតូចទាំងធំគ្រប់រូបា
ដឹកនាំនាវាកម្ពុជា សូមពិចារណាឲ្យប្រយ័ត្ន ។
ជាតិខ្មែរបាត់បង់អស់ទឹកដី ទ្រព្យមានតម្លៃច្រើនអនេក
រេចរឹលថោកទាបព្រោះបែកបាក់ រហូតដល់ថ្នាក់កញ្ឆះគេ ។
ឥឡូវសហប្រជាជាតិ នាំគ្នាខ្មីឃ្មាតជួយរិះរេ
រួបរួមជាតិខ្មែរឲ្យស្ថិតស្ថេរ រុងរឿងដូចគេតរៀងទៅ ។
យើងខ្មែរត្រូវរួមសាមគ្គា សាមគ្គីគ្នាទាំងក្នុងក្រៅ
អ្នកមានអ្នកក្រចេះល្ងង់ខ្លៅ សម្បុរសខ្មៅខ្មែរដូចគ្នា ។
កុំចេះព្វកែតែម្នាក់ឯង ត្រូវក្រែងដល់អ្នកមានវិជ្ជា
បើកឲ្យគេជួយគិតច្រើនគ្នា សាងកម្ពុជាបានសុខសាន្ត ។
កុំស្រឡាញ់បុណ្យជាងជាតិខ្មែរ កុំមើលឃើញតែទ្រព្យធនធាន
កុំគិតតែបក្ស ញាតិសន្តាន គិតជាតិថ្កើងថ្កានប្រសើរគាប់ ។
កុំលុះដោយអគតិធម៌ ខ្មៅទៅជាសនាំអភ័ព្វ
សុចរិតស្មោះត្រង់កាន់ឲ្យជាប់ ទុកជាទម្លាប់អ្នកសាងជាតិ ។
កុំគិតច្រណែនប្រែងជើងគ្នា កម្មពៀរវេរាមិនរលាត
ទុក្ខកម្ពុជាមិនឃ្លាឃ្លាត យើងកសាងជាតិមិនកើតទេ ។
អ្នកអាក្រក់ល្អ សឬខ្មៅ រាស្ត្រនាំគ្នាទៅគិតគ្នាន់គ្នេរ
រាស្ត្រអ្នកដាក់តម្លៃឲ្យទេ យើងល្អជាងគេគង់តែបាន ។

យើងស្រឡាញ់ជាតិត្រូវស្តាប់រាស្ត្រ  កុំធ្វើផ្តេសផ្តាសពាលសាមាន្យ
កុំទុកដាក់រាស្ត្រដូចតិរច្ឆាន  ការអម្បាលម៉ានស្រេចចិត្តខ្លួន ។
យើងចង់ឲ្យជាតិយើងលូតលាស់ ចំរើនភោគភ័ស្តុរឹងមាំមួន
ត្រូវយកសម្លេងរាស្ត្រជាក្បួន  កុំតាមចិត្តខ្លួនមិនកើតទេ ។
អ្នកឥតបញ្ញាភ្លឺថ្លាយង់  ត្រូវហ៊ានលះបង់ទុកឲ្យគេ
កុំក្រាញចង់ធំមិនល្អទេ  ជាតិយើងខ្ញុំគេទៀតមិនខាន ។
ថៃគេមិនក្រាញដូចយើងទេ  ជាតិគេគង់វង់រុងរឿងបាន
រៀនសូត្រតាមគេខ្លះកុំខាន  ដើម្បីជាតិបានសុខសាន្តអឺយ ។
ចំរើនពរមកខ្លីប៉ុណ្ណោះ  សូមស្លេះសេចក្តីឈប់សិនហើយ
សូមអ្នកដឹកនាំកុំកន្តើយ  វាសនាខ្មែរអើយផ្ញើលើអ្នក ៕

២០ ធ្នូ ៩១

# ការខាវប៉ុនភ្នំមិនគិត នៅគិតឯស្ករកំបែកមាត់

ការស្រុកទេសធំ ការងារប៉ុនភ្នំ មិននាំគ្នាគិត
ការងារស្លាប់រស់ អាយុជីវិត មិននាំគ្នាគិត
គិតតែសប្បាយ ។
គិតពួកគិតបក្ស គិតបុណ្យគិតសក្តិ គិតមាសប្រាក់ចាយ
គិតឡើងសម្តេច គិតចង់ពាក់ផ្កាយ គិតចង់សប្បាយ
ស៊ីផឹកស្រាស្រី ។
គិតរាំគិតរែក នឹងស្ករកំបែក មាត់ធ្វើពីដី
មិនគិតជាតិស្លាប់ អាប់ឱនរស្មី ជាតិខ្មែរប្រុសស្រី
រងទុក្ខហួសថ្លែង ។
គួរឲ្យអៀនខ្មាស គួរឲ្យអាម៉ាស់ គួរឲ្យចំបែង
ជាតិខ្មែរធ្លាប់ថ្កើង សៀមយួនស្ញប់ស្ញែង ឥឡូវគេលែង
ខ្លាចក្រែងខ្មែរហើយ ។
គេមើលងាយខ្មែរ ដូចកញ្ឆះគេ មិនដឹងទេឡើយ
លោកអ្នកដឹកនាំ ល្មមភ្ញាក់ខ្លួនហើយ ខ្មែរទុក្ខឥតស្បើយ
ដោយសារលោកអ្នក ។
នាំគ្នាក្រោកឡើង កុំនៅសើងម៉ើង យល់ការណ៍ឲ្យជាក់
ឈប់គិតបក្សពួក ឈប់គិតបុណ្យសក្តិ ឈប់គិតមាសប្រាក់
គិតជាតិជាធំ ។

ប្រមូលគ្នីគ្នា រួបរួមសាមគ្គា សាមគ្គីជួបជុំ
ខ្មែរបេះខ្មែរល្វង់ ខ្មែរតូចខ្មែរធំ រួមប្រមូលផ្តុំ
នាំគ្នាសាងជាតិ ។

បើធ្វើដូចនេះ ទុក្ខសោករបេះ បាត់បង់ឃ្លាឃ្លាត
ជួបជុំវង្សា និង គណាញាតិ ខ្មែរយើងថ្កើងទៀត
ពិតពុំខានឡើយ ៕

២៤ កុម្ភៈ ៩៤

ឥ៚ឲ

## ល្អពុម្ពល្អព្រះ

ល្អពុម្ពល្អព្រះ តូចធំស្តើងក្រាស់ សមឬមិនសម
ស្រេចនៅលើពុម្ព ដែលជាងខិតខំ គិតគូរឆ្លាក់ផ្សំ
ជាពុម្ពនោះឯង ។

ធ្វើពុម្ពបានល្អ ព្រះស្អាតបវរ ល្អល្អះចិញ្ចែង
ឆ្លាក់ពុម្ពយ៉ាងណា ព្រះយ៉ាងនោះឯង ដូចពុម្ពជាក់ស្តែង
គ្មានខុសត្រង់ណា ។

ម៉ែឪជាពុម្ព　　រីអ្នកដឹកនាំ　　ជាពុម្ពដូចគ្នា
កូនចៅប្រុសស្រី　　និង ពួកប្រជា　　ជនទាំងអស់គ្នា
ធ្វើត្រាប់តាមពុម្ព ៕

១៣ មេសា ៩៦

## តើគិតយ៉ាងណា

ដីខ្មែរពីដើម　　រីកធំសម្បើម　　ទៅគ្រប់ទិសា
ខាងជើងទល់ចិន　　ខាងលិចភូមា　　ខាងទិសបូព៌ា
ទល់នឹងសមុទ្រ ។

មិនមែនតែដី　　វប្បធម៌ក៏ល្បី　　ខ្ពង់ខ្ពស់បំផុត
ប្រាសាទសិលា　　ថ្លៃថ្លាជាមកុដ　　ប្រសើរវិសុទ្ធ
នៅក្នុងលោកា ។

ជាតិសៀមនិងយួន　　ធ្លាប់មកជ្រកកោន　　ក្រោមម្លប់ចេស្តា
ចម្លងចំណេះ　　សិល្បៈវិជ្ជា　　វប្បធម៌នានា
ពីជាតិខ្មែរយើង ។

ប៉ុន្តែសព្វថ្ងៃ　　ដោយគេចេះថ្លៃ　　ប្រឹងប្រែងឡើង
ជាតិគេចំរើន　　រុងរឿងថ្កុំថ្កើង　　គេលែងស្គាល់យើង
ដូចមុនទៀតហើយ ។

មាត់គេរាប់អាន ចិត្តពាលសាមាន្យ គ្មានស្មោះត្រង់ឡើយ
គេគិតលេបយក ទឹកដីយើងហើយ បងប្អូនខ្មែរអើយ
តើគិតយ៉ាងណា ? ។

ដេកលក់មិនភ្ញាក់ ស្រវឹងពួកបក្ស យសសក្តិស្រីស្រា
ស្រវឹងអំណាច ស្រវឹងទ្រព្យា ស្រវឹងឈ្មោះគ្នា
សម្លាប់ជាតិឯង ។

បើមិនភ្ញាក់ខ្លួន ទឹកដីបានយួន និងសៀមមិនលែង
ព្រោះយើងស្រវឹង ដើរខុសខ្លួនឯង កើតទុក្ខចំបែង
តក្កូនតចៅ ។

ភ្ញាក់ឡើងក្រោកឡើង បងប្អូនខ្មែរយើង ទាំងក្នុងទាំងក្រៅ
សាមគ្គីមូលមិត្រ ឥតមានហ្មងសៅ កំចាត់សត្រូវ
លេបទឹកដីយើង ៕

១៨.១២.០៤

ភិក្ខុ ធិន ភេន ឥន្ទបញ្ញោ

# អ្នកដឹកនាំល្អ

អ្នកដឹកនាំល្អ កម្រ រក បាន ផ្តល់ក្តីសុខសាន្ត ថ្កើងថ្កានសង្គម
ជាតិនិងសាសនា ថ្លៃថ្លាជួបជុំ ជិតឆ្ងាយនិយម តូចធំសរសើរ ។
សាកល្បងថ្នាថ្លែង សំដែងសេចក្តី គំនិតវែងខ្លី អាស្រ័យដំណើរ
ផ្លូវលោកផ្លូវធម៌ នឹង ន ប្រសើរ ពិភពលោកដើរ ស្មោះស្មើស្ម័គ្របាន ។
កំណើតគំនិត ប្រព្រឹត្តដឹកនាំ ដំណើរមាំទាំ ស៊ូទ្រាំ ប្រមាណ
គោលការណ៍ ធំៗ ធ្វើពុំងាយបាន ស្រុកយើងខកខាន មិនបានប្រើឡើយ ។
លោកអ្នកដឹកនាំ គាំទ្រប្រើបុះ គំនិតបំរុះ កើតដុះ យូរហើយ
ប្រទេសជឿនលឿនចំពីនត្រាណត្រើយ ប្រើមិនកន្តើយល្វែល្វើយលូតលាស់ ។
ឯករាជ្យអធិបតេយ្យ ទឹកដី ជាដើម គំនិតសម្បើម ចាប់ផ្តើម ពីមនុស្ស
គ្មានព្រហ្មលិខិត ករិតសង្គ្រោះ ឬឱ្យរោយរុះ ទាបខ្ពស់សង្គម ។
ស្រុកយើងក៏អាច សំរេចប្រើបាន របៀបថ្កើងថ្កាន ប្រមាណសមរម្យ
នយោបាយ សេដ្ឋកិច្ច ចាំបាច់សង្គម គំនិតធំៗ ដឹកនាំ ស្ម័គ្រស្មោះ ។
ប្រជាធិបតេយ្យ សេរី យុត្តិធម៌ អំណាច នឹង ន ល្អមិនចន្លោះ
កុំប្បាំងគ្នាឯង ត្រូវក្រែងស្រណោះ ខ្លាចបាត់បង់អស់កោះកោះដីទឹក ។
កាលណាធ្វើកើត ចាយចេតខ្ពង់ខ្ពស់ ល្បីល្បាញក្តៅឈ្មោះ ពិរោះពន្លឹក
មហាជនគាំទ្រ ជូនពរសន្ទឹក ស្លាប់ទៅគេនឹក រំលឹកគុណពីក្រោ។

អ្នកដឹកនាំល្អ បវរថ្លៃថ្លា របស់ខេមរា កិច្ចការ ផែនដី

ដោយប្រជារាស្ត្រ ជ្រើសរើសសេរី　　សំរាប់ប្រុសស្រី ដើម្បីជាតិខ្មែរ ។
កំណើតគំនិត ខ្មែរពិតប្រាកដ　　អ្នកមានអ្នកខ្សត់ ជនបទស្រុកស្រែ
អ្នកក្រុងតូចធំ ជិតជុំជាតិខ្មែរ　　តំណាងជូនថៃ មិនកែប្រែឡើយ ។
ទទួលតំណែង តឹងតែងបន្ទុក　　ដឹកនាំឈានមុខ រាស្ត្រទុកចិត្តហើយ
ភាគច្រើនសម្លេង ចាស់ក្មេងចម្លើយ　　ជូនមិនកន្តើយ មិនស្បើយបោះឆ្នោត ។
ខិតខំបម្រើ ប្រសើរ ការងារ　　ប្រយោជន៏ប្រជា មិន រា រេ ណោត
ដើម្បីជាតិយើង រុងរឿងគួរកោត　　លែងមានចំណោទចាក់ដោតទាស់ទែង។

អ្នកដឹកនាំល្អ បេះ ក បេះ សាង　　សន្តិភាពស្អិតស្អាង មិនច្បាំងប្រជែង
យោគយល់អប់រំ តូចធំចាស់ក្មេង　　រួបរួមលោះលែង ព្រមព្រៀង សាមគ្គី។
បេះរស់នឹងគ្នា សុខជាមិនឈ្លោះ　　ស្រុះស្រួលមិនទាស់ រើគាស់រក្តី
ខ្មែរហើយនឹងខ្មែរ ក្រុងស្រែមូលមីរ　　សន្តោសគ្នាគ្នី ពេញទី ស្រុកទេស ។
មានការផ្សព្វផ្សាយ ចែកចាយពត៌មាន　　អប់រំវិញ្ញាណ រាប់លានមិនធ្វេស
បំបាត់មន្ទិល ភ្ញាក់ផ្អើលបរទេស　　ជំនឿបេស ក្រឡាស់រកធម៌ ។
ផ្តល់សេរីភាព លើកប្រៀបមហាជន　　អស់ក្តីបំភាន់ ជិះជាន់ភូតភរ
ទូទៅរាស្ត្រខ្មែរ ស្គាល់តែយុត្តិធម៌　　ទូទាំង នគរ នឹង ន រីករាយ ។
បង្រួបបង្រួម តូចធំជិតឆ្ងាយ　　ក្រុមបក្សទាំងឡាយ មិនណាយរាយមាយ
បេះការពារគ្នា គ្រប់គ្រាមានភ័យ　　មិនគិតលកលៃ តែផ្ទៃបក្សខ្លួន ។
ធ្វើឲ្យព្រមព្រៀង តរៀងជានិច្ច　　មិនឲ្យភ្លាំងភ្លេច កែគេចអាសន្ន
បរទេសជិតឆ្ងាយ ប្រញាយលួចប្លន់　　ដោះស្រាយរួសរាន់ ឲ្យទាន់ពេលា ។

អ្នកដឹកនាំល្អ ត្រេកអរឧបត្ថម្ភ　　ជីវភាពសុខដុម ថ្កើងថ្កុំប្រជា
មានចិត្តសប្បាយ ជិតឆ្ងាយគ្រប់គ្នា　　គន្លងធម្មា វមនា ព្យាយាម ។
គិតគូរឱកាស លូតលាស់សេដ្ឋកិច្ច　　ខ្មែរមានមិនតិច សម្បត្តិ មាំទាំ
កម្មសិទ្ធិគ្រួសារ រដ្ឋា ណែនាំ　　អំណាចសន្សំ គាំពារជាតិបាន ។
លៃលកថវិកា ចំណារចំណាយ　　ទិញដូររៀងអាយ ថ្លឹងថ្លៃប្រមាណ
បែកគ្រប់ក្រសួង ទំនង តាមដាន　　អាទិភាពកុំខាន ឱ្យបានត្រឹមត្រូវ ។
កុំឱ្យជំពាក់ មាសប្រាក់បរទេស　　លិចលង់ព្រោះធ្វេស ប្រហែសល្ងង់ខ្លៅ
ធ្លាក់ខ្លួនសុំទាន ធនធានក្នុងក្រៅ　　សុវណ្ណភូមិឆ្អិនឆ្អៅ មិនត្រូវអន់ក្រ ។
នាំជាគំរូ សីលធម៌ត្រឹមត្រូវ　　ខ្មែរដើរតាមផ្លូវ ម៉ែឪ ល្អះល្អ
មិនមានខុសឆ្គង គន្លងព្រះធម៌　　ព្រះពុទ្ធបវរ តំណ ប្រពៃ ។

អ្នកដឹកនាំល្អ បង្ក លក្ខខ័ណ្ឌ　　អំណាចស្ថាប័ន សំខាន់ទាំងបី
និតិបញ្ញត្តិ ប្រតិបត្តិ ដោះស្រាយ　　តុលាការកាត់ក្តី សេរីឯករាជ្យ ។
សភាទាំងពីរ ម្នាម្នីតែងច្បាប់　　ប្រសើរចំណាប់ សំរាប់ សំរេច
ប្រយោជន៏រដ្ឋា មហាជនចាំបាច់　　សមគួរជាប់ស្រេច អង្គស្តេចឡាយបាន ។
រដ្ឋាភិបាល សម្រាលបន្ទុក　　កិច្ចការគ្រប់មុខ សុខទុក្ខ ប៉ុន្មាន
ក្នុងគន្លងច្បាប់ សណ្តាប់សន្តាន　　ដែលសភាបាន មិនខានតាក់តែង ។
អង្គតុលាការ អាជ្ញាវិនិច្ឆ័យ　　កិច្ចការអ្វីៗ កាត់ក្តី ជាក់ស្តែង
កិច្ចការរដ្ឋបាល ប្រមើលគិតក្រែង　　មិនឱ្យបាត់បែង ក្លាយក្លែងច្បាប់កែ ។

អ្នកដឹកនាំល្អ ចិត្តធម៌ ប្រពៃ ក្រុងស្រែវាលព្រៃ លកលៃធូនថែ
សមុទ្រទន្លេ ជ្រោះជ្រៃ ភ្នំ ខ្មែរ មនុស្សសត្វហូរហែ ផ្កាផ្លែ លូតលាស់ ។
មូលធនស្រុកទេស មិនធ្វេស រក្សា កែប្រែស្ថាបនា ផែនការសង្គ្រោះ
ធនធានធម្មជាតិ ធ្លាក់ធ្លៀតមិនលោះ ព្រៃឈើសត្វរស់ មិនគាស់កាប់ឆ្ការ ។
មូលធនមនុស្សម្នា ការងារឧបត្ថម្ភ សាលារៀបចំ សន្សំប្រាជ្ញា
បេះដឹងឱ្យច្រើន ឱ្យកើនកិច្ចការ គិតគូរជ្ញា ជួយស្តារសង្គម ។
ធនធានវប្បធម៌ ត មក៏ យូរយារ មតិកមហិមា គ្រប់គ្រា ណែនាំ
រក្សាប្រាសាទ បទបាទច្រៀងរាំ ភាសាថែទាំ លំនាំស្លៀកពាក់ ។
មូលធនសង្គម តូចធំអង្គការ សមាគម សាលា ក្រឡាប្រទាក់
វត្តអារាមលោក ចែវចូកត្រៃលក្ខណ៍ គ្រួសារពឹងពាក់ ជួយអ្នកក្រោបាន ។
ធនធានមនុស្សសាង គ្រប់យ៉ាងឱ្យកែ លំអទ្រព្យខ្មែរ ត្រូវថែ គ្រឹះស្ថាន
ធំៗ ផ្លូវស្ពាន សំណង់ជ្រើងថ្កាន ខ្វាយខ្វល់បរិដ្ឋាន ឧទ្យានទេសចរណ៍ ។

អ្នកដឹកនាំល្អ បង្ក លក្ខណៈ ចាត់ចែងមិនអាក់ ទុកដាក់យុទ្ធករ
ក្រោមស៊ីវិលរដ្ឋ ទៀងទាត់បានល្អ មិនធ្វើលកុះករ ឈ្លូច យោធា ។
ផ្តល់ឯករាជភាព រយរៀបតុលាការ ពីដៃរដ្ឋា ភិបាលពានពារ
កិច្ចការកាត់ក្តី ចម្លើយនានា ចែកដាច់មុខងារ រួមគ្នា មិនល្អ ។
ផ្តល់ជូនសេរី បេញស្តីពត៌មាន យោបល់ទិតៀន ប្រិតប្រៀនស្មោះសរ
តំណាងមហាជន គន់រកឧក្រិដ្ឋករ ជួយកែលំអ អាជ្ញាធរលើក្រោម ។
ជូនសិទ្ធិប្រុសស្រី ពេញវ័យបោះឆ្នោត ត្រឹមត្រូវមិនចោត អាចផ្តោតអារម្មណ៍

មួយអាណត្តិម្តង អាចផ្សងលើក្រោម ប្តូរអ្នកដឹកនាំ ដោកដាំអំណាច ។
តំកល់តំកើង ជ្រោងឡើងប្រជា ប្រយោជន៍ភារា កម្ពុជាអង់អាច
ខ្ពស់លើសអ្វីៗ ជិតឆ្ងាយកើតលិច ធំជាងអំណាច ជាងប្រាជ្ញខ្លួនផ្ទាល់ ។

អ្នកដឹកនាំល្អ ស្មោះសរ សទ្ធា ជឿព្រះធម្មា ល្អជា កុសល
ជឿបុណ្យជឿបាប តាមច្បាប់កម្មផល បដិបត្តិជិតដល់ ហេតុផលការងារ ។
គោរពព្រះសង្ឃ ត្រឹមត្រង់ ស្រុះស្រួល ឧបត្ថម្ភ សំរួល ទទួល ធម្មា
ខ្មែរអ្នកចេះដឹង ប្រែងប្រឹងការងារ ជួយថែរកម្ពុជា គ្រប់គ្រាតូចធំ។
ជូនតួនាទី មូលមីរ វត្តវ៉ា ព្រះពុទ្ធសាសនា ជួយស្តារសង្គម
បំណុះជើងវត្ត ទៀងទាត់ជួបជុំ ជ្រោមជ្រែងសហគមន៍ មាំទាំជីវភាព។
ប្រគេនអធិបតេយ្យ សេរីផ្ទូរផង់ កិច្ចការព្រះសង្ឃ ផ្ដឹតផ្គង់រយរៀប
អប់រំសាសនា សីលធម៌របៀប ជ្រោងសកម្មភាព ពេញប្រៀបគុណធម៌។
ឲ្យបានសមស្រប ប្រកបមាត្រា ធម្មនុញ្ញរដ្ឋ សាសនាបវរ
ជាសាសនារដ្ឋ ប្រាកដ ល្អះល្អ កុំមានកករ វឹកវរគ្រួតគ្រា។

អ្នកដឹកនាំល្អ ស្មោះសរ ពេកក្រៃ កិច្ចការរាល់ថ្ងៃ អាស្រ័យមាត្រា
តាមច្បាប់ទម្លាប់ គួរគាប់អាជ្ញា ដែនដីកិច្ចការ ថ្លៃថ្លា លទ្ធផល ។
ខុសត្រូវទទួល សំរួល សំរេច សព្វសារភារកិច្ច ថ្លឹងល្បិចយោបល់
ដំណើរទំនង ផ្លូវផ្គងលទ្ធផល វិបាក មិនសល់ កិច្ចកល គ្រប់គ្រា ។
ដឹងខ្មៅ ដឹង ស ដឹង ក្រ ដឹង មាន ប្រមាណធនធាន វិញ្ញាណ ប្រជា

ចំណូលចំណាយ ជិតឆ្ងាយ ការងារ
ប្រយោជន៍ភារា ទុកជា សិរសា ។
ដឹងកិច្ច ដឹងកល យល់ ៨ ល្បិច គេ
បរទេសរិះរេ ដី កេរ ដូនតា
ប្រុងប្រៀបការពារ រួមគ្នា ខេមរា
ធ្វេសស្តាំក្តីណា រក្សា មិនឃ្លាត ។
លេះលោភ លេះកើ កុះករ ប្រមូល
ធ្វេសស្តាំចុះចូល ក្នុងគោលការណ៍ជាតិ
ប្រយោជន៍ខ្មែរយើង រុងរឿងខ្ទីឃ្នាត
ជៀសវាងវិវាទ ជ្រែកជ្រៀតក្នុងក្រៅ ។
លេះបែងលេះបែក ឲ្យដាច់ពីគ្នា
សត្រូវកម្ពុជា គ្រប់គ្រាចិត្តខ្មៅ
ពីគូប្រជែង ខ្មែរឯងសំដៅ
តំណែងចៅពៅ មិនត្រូវ កំទេច ។
មានចិត្តត្រេកអរ បង្ក លក្ខណៈ
ខ្មែរគ្រប់ជាន់ថ្នាក់ ស្មោះស្ម័គ្របំណែក
ថ្លៃថ្នូរកិច្ចការ អាជ្ញា បែងបែក
ចូលរួមបំណែក ទូលរែក កុះករ ។
អារកាត់ រើសយក៏ យុត្តិធម៌ចាត់បែង
រង្វាន់តាក់តែង ដាក់ស្តែងអ្នកល្អ
ទណ្ឌកម្មអ្នកខូច ប្រយោជន៍តំណ
គំរូរៀងត បវរបែបបទ។

អ្នកដឹកនាំល្អ មាន ១ សន្យា
អាណត្តិ កិច្ចការ អាជ្ញាកំណត់
ពីរ ឬ បីដង បំណងប្រាកដ
ប្រឹងប្រែងម៉ត់ចត់ បុងផុតលាថយ ។
រៀបចំ ការល្អ បន្ត ពនគ្នា
ផ្ទេរកិច្ចការងារ អ្នកជាជាន់ក្រោយ
ស្រុះស្រួលចាត់ចែង ដំណែងទុកឲ្យ
កិច្ចកលមេកោយ ជូនដោយស្មោះត្រង់។
អ្នកក្រោយទទួល សុខស្រួល បន្ត
មិនល្អក់កករ ការល្អផ្ចិតផ្ចង់
ផ្លាស់ប្តូររដ្ឋបាល ឈើធ្លាលត្រឹមត្រង់
ដឹកនាំតម្រង់ បំណង សម្បើម ។
គិតគូរការល្អ បន្ត កិច្ចការ
រដ្ឋបាលអាជ្ញា មុនចារ ចាប់ផ្តើម
ប្រយោជន៍ជាតិខ្មែរ កុនកែជង្គើម
បញ្ចប់ចុងដើម ដំណាំដុះដាល ។

អ្នកដឹកនាំល្អ កម្រ រកបាន នេះបរិយាសាន ដែលបានតំណាល
រៀបរាប់គោលៗ ប្រមូលពីថ្នាល កិច្ចការរដ្ឋបាល សម្រាលចម្ងល់ ។
បីវគ្គចុងក្រោយ ថ្លែងដោយបំរុះ ភាគច្រើនមានដុះ ជាប់ចុះចិត្តឆ្ងល់
ផ្ទាល់ខ្លួនពិសោធន៏ នៅចោតខ្វាយខ្វល់ រួមទឹងយោបល់ កិច្ចកលនយោបាយ ។
តាមការប្រិតប្រៀន សូត្ររៀនរស់នៅ ឆ្ងាយពីស្រុកទៅ ចិត្តនៅអាល័យ
ក្នុងសាមសិបឆ្នាំ ចងចាំរាល់ថ្ងៃ ស្រុកយើងថ្លាថ្លៃ គុណស្រ័យកន្លង ។
បារទុកជូនអាន គ្រាន់បានគំនិត គោលៗ ទុកគិត ប្រព្រឹត្ត ហ្មត់ហ្មង
លោកអ្នកដឹកនាំ សូមគាំពារផង រក្សាបំណង ច្បាស់ច្បងគោលការណ៏ ។
គ្មានប្រាថ្នាអ្វី ពីស្តីបរិយាយ ជួយខ្មែរជិតឆ្ងាយ ដោះស្រាយ ប្រស្នា
គ្រប់កាលវេលា វេទនាសុខា ជួយស្រាយបញ្ហា ប្រស្នាដឹកនាំ ។
សូមលោកអ្នកអាន ខន្តីមេត្តា អភ័យទោសា ប្រការឆ្គងឆ្គាំ
ដល់អាត្មាខ្ញុំ រកផ្សំ ពាំនាំ គំនិតដឹកនាំ មាំទាំ មកនេះ ។
ហើយសូមជូនពរ នូវធម៌ប្រសើរ មង្គលដំណើរ ប្រសើរវិសេស
លោកអ្នកដឹកនាំ គាំពារប្រទេស កុំបីមានធ្វេស ពេលនេះទៅមុខ ។
ពិសេសណាស់ទៀត ប្រសិទ្ធិពរ សួស្តីព្រះធម៌ បវរ ផុតទុក្ខ
ស្រុកម្តាយកម្ពុជា គ្រប់គ្រាទៅមុខ សូមខ្មែរផុតទុក្ខ បានសុខរៀងទៅ ។

ព្រះអគ្គ ឫទ្ធិពល នាថបណ្ឌិតោ
(ក្រុងប៉ារីស ២៤ មីនា ២០០៥)

# លោកអ្នកសប្បុរស ដែលជួយឧបត្ថម្ភការបោះពុម្ព

១-លោកស្រី ឡោត គីរីកញ្ញា ព្រមទាំងបុត្រ អេឌ័រ ឧត្តម ៥០€
២-ឧបាសិកា អ៊ុច ជួង ២០ €
៣-ឧបាសិកា ឡាយ រ៉ិ ៣០ €
៤-លោក និង លោកស្រី តាវ ឃុនហៀង ៥០ €
៥-លោក LY ALAIN ៦០ €
៦-លោក ឱ កុសលៈ និង កូន ចៅ
ឧទ្ទិសកុសលចំពោះ លោកស្រី ស សាព្រើង ២០០ €
៧-លោក ខៀវ ឡេង និង កូន ចៅ
ឧទ្ទិសកុសលចំពោះ លោកស្រី ម៉ៅ សរិតា ២០០ €
៨-អស់លោក ជាកូនចៅ ឧទ្ទិសកុសលចំពោះ
ឧបាសក ប៊ុន ថាន់ ៣០០ €
៩-ឧបាសក តាន់ ណាំ ឧបាសិកា លិម ឆេង អ៊ី ៥០ $
១០-ឧបាសិកា ឃី អេងឡាំ ២០ €
១១-លោក និង លោកស្រី ឱ សុមេធា និង បុត្រ ១០ €
១២-លោក និង លោកស្រី ស្វង ណារឿន ២០ €
១៣-ឧបាសិកា ឡាយ សេងហាក់ ២០ €
១៤-ឧបាសិកា ឃិន សុត ៥០ €
១៥-ឧបាសិកា ឈា ឆេងលន់ និង នាងមុំ ២០ €
១៦-ឧបាសិកា គីម សុផន និង គ្រួសារ ៣០ €

| | |
|---|---|
| ១៧-ឧបាសិកា អ៊ឹង អាង | ២០ € |
| ១៨-ឧបាសិកា ឈា ឆាត់ឌី | ២០ € |
| ១៩-លោកនិងលោកស្រី ង៉ី ហុក និង បុត្រធីតា | ២០ € |
| ២០-អាចារ្យ មិន ធូ ឧបាសិកា តាំង រួចបៅ | ២០ € |
| ២១-ឧបាសិកា ចាន់ ណាត | ២០ € |
| ២២-ឧបាសិកា គង់ ធួក | ២០ € |
| ២៣-ឧបាសិកា ម៉ៅ ទៀង និងស្វាមី | ៥០ $ |
| ២៤-អ៊ិន សាផុន និង គ្រួសារ | ៥០ € |
| ២៥-ឧបាសិកា ជូ ម៉ាក់ | ២០ € |
| ២៦-ឧបាសិកា ប៉ែ លិន | ២០ € |
| ២៧-ឧបាសិកា ឃិន ហុកទីវ | ២០ € |
| ២៨-ឧបាសិកា យី ចាន់ដារ៉ា | ២០ € |
| ២៩-ឧបាសិកា អាត អេង | ១៥ € |
| ៣០-ឧបាសិកា អ៊ឹង ម៉ាឡេង | ២០ € |
| ៣១-លោក ម៉ម សិរីសុខា និង គ្រួសារ | ២០ € |
| ៣២-លោក ម៉ម ខេមរិន្ទ្រ និង គ្រួសារ | ២០ € |
| ៣៣-លោក ឃុន សារុន | ២០ € |
| ៣៤-លោក អ៊ិន សារ៉េន និង ភរិយា | ១៥ € |
| ៣៥-លោក ជួន ទីម អ្នកស្រី ទិត ពៅ | ២០ € |
| ៣៦-ឧបាសិកា ឃុន តាំងអ៊ឹម | ១០ € |

| | |
|---|---|
| ៣៧-ឧបាសិកា ទី វណ្ណហង្ស | ១៥ € |
| ៣៨-ឧបាសិកា យ៉ាន ហ៊ុន | ១០ € |
| ៣៩-ឧបាសិកា សេក ហេង | ១០ € |
| ៤០-លោក និង លោកស្រី ស៊ាម ហ៊ុច | ១៥ € |
| ៤១-លោក និង លោកស្រី កៀវ ម៉ារី និង បុត្រធីតា | ២០ € |
| ៤២-ឧបាសិកា ឈុន ស៊ីវហ៊ាង | ២០ € |
| ៤៣-ឧបាសិកា នៅ ទាវខេង និង បុត្រធីតា | ២០ € |
| ៤៤-ឧបាសិកា សៀប គីមហ៊ាង | ១៥ € |
| ៤៥-ឧបាសិកា ណែម លិមអ៊ាន | ២០ € |
| ៤៦-ឧបាសិកា ណែម លិមអ៊ុន | ២០ € |
| ៤៧-ឧបាសិកា អៀង ហុង | ១៥ € |
| ៤៨-ឧបាសិកា ហ៊ុល ឃុត | ១៥ € |
| ៤៩-ឧបាសិកា ប៊ួ ដាណារ៉េត | ១៥ € |
| ៥០-ឧបាសិកា គួ អៀនី | ១៥ € |
| ៥១-ឧបាសិកា សុត សុផានី | ១៥ € |
| ៥២-ឧបាសិកា ស៊ុន តាំងគុយអេង | ១៥ € |
| ៥៣-ឧបាសិកា ហុង ធិន ហៅ ពៅ | ១៥ € |
| ៥៤-ឧបាសិកា នេត្រ គួន | ២០ € |
| ៥៥-លោក ទេព សំផន និង ភរិយា | ១០ € |
| ៥៦-ឧបាសក ឡៅ ហេង ឧបាសិកា តាន់ សាយយុត | ១៥ € |

៥៧-អ្នកស្រី ឡៅ សាយយឹម ១៥ €

៥៨-អ្នកស្រី ងីប ហុងយ៉េង ១៥ €

៥៩-អ្នកស្រី ឡៅ ហុងស៊ីម និង បុត្រធីតា ១៥ €

៦០-លោក ផុង ហុងកៅ អ្នកស្រី ឡៅ ហុងឡាយ ១៥ €

៦១-ផុង សូធីថា និង សុន ណារេត ៨ €

៦២-ឧបាសិកា ញឹក សាយ៉ាន់ ១៥ €

៦៣-ឧបាសិកា ហួ គិមឡេង ១៥ €

៦៤-លោកស្រី អ៊ូ បុប្ផ ព្រមទាំងស្វាមី ១៥ €

៦៥-នាង នង ស៊ីនេត ១០ €

៦៦-លោកស្រី អ៊ូ យុវតី ព្រមទាំងស្វាមី ១០ €

៦៧-លោកស្រី អ៊ូ គង់ធីតា ព្រមទាំងស្វាមី ១០ €

៦៨-លោក អ៊ូ ទិត្យា ព្រមទាំងភរិយា ១០ €

៦៩-នាង កញ្ញា សាគូ បុប្ផវតី ៥ €

៧០-នាង កញ្ញា សាគូ បុប្ផទេវី ៥ €

៧១-អ្នកស្រី ប៉ាវ សារ៉ែន ២០ €

៧២-អ្នកស្រី ម៉ី ផាសូរី ១០ €

៧៣-លោក និង លោកស្រី ឌិម ស៊ីថា ១៥ €

៧៤-ឧបាសក ញាណ ឆាន និង ភរិយា ១៥ €

៧៥-ឧបាសក ណៃ ហួរ ២០ €

៧៦-ដូនជី សុក ចម ចារួន និង បុត្រធីតា ១០ €

៧៧-ជូនជី ហ្វួត សាយហ៊ុន និង បុត្រធីតា ១០ €

៧៨-អ្នកស្រី សុក ចម នារី និង ស្វាមី បុត្រធីតា ១០ €

៧៩-ឧបាសិកា ឡេង ចេង ៥ €

៨០-លី អៀង ខេង ៥ €

៨១-Tea Kunthea ៥ €

៨២-Tong Salan ៥ €

៨៣-Marie Frane ៥ €

៨៤-Mr. Keo Re ៥ €

៨៥-ឆាយ គីមស្រ៊ី ២០ €

៨៦-ស៊ុន មេងស្រ៊ុន ២០ €

៨៧-យាយ ងាន់ ២០ €

៨៨-ឈាង ហេង អេង ហៅសុខ ២០ €

៨៩-Mr. Lim Chay ១៥ €

៩០-លោក តាន់ កាង អ្នកស្រី ខា ណុកយិប ១៥ €

៩១-ប៊ុត សុគន្ធា ជា សុគន្ធា ១០ €

៩២-ភិក្ខុ ងិន ភេន ឥន្ទប្បញ្ញោ ២០ €

យើងខ្ញុំ សូមឧទ្ទិសចំណែកបុណ្យកុសលនេះ ចំពោះលោក អ្នក ដ៏មានគុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតា ជាដើម ព្រមទាំងញាតិមិត្រទាំងឡាយផង ។ សូមលោក អ្នកដ៏មានគុណ មានមាតាបិតា ជាដើមនោះ អនុមោទនាទទួលយកនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្ដីជ្រះថ្លារៀងៗខ្លួន កុំបីខាន ៕



## ប្រវត្តិខ្លះ របស់ អ្នកនិពន្ធ

ភិក្ខុ ងិន ភេន កើតថ្ងៃអាទិត្យ ៨ តុលា ១៩២៨ ក្នុងឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវ ។ ឪពុកឈ្មោះ រ័ត្ន ងិន ម្ដាយឈ្មោះ ម៉ៅ ង៉ែត របររកស៊ីធ្វើស្រែ។

-បានរៀនចប់នៅសាលាវត្តក្នុងឃុំរបស់ខ្លួន បានចូលរៀនធម្មវិន័យ និង បានសមាទានសីល ២ ឆ្នាំ រួចហើយបានចូលបួស... បានសិក្សា ប្រឡងជាប់សញ្ញាប័ត្រ សាលាបាលីជាន់ខ្ពស់ ក្រុងភ្នំពេញ ។

-បានទទួលអាហារូបករណ៍ទៅបន្តការសិក្សានៅ មហាមកុដរាជវិទ្យាល័យ ប្រទេសថៃ អស់ពេល ៨ ឆ្នាំ ប្រឡងជាប់សញ្ញាប័ត្រ សាសនសាស្ត្របណ្ឌិត និទ្ទេសកិត្តិយស ។

-ត្រឡប់មកកម្ពុជាវិញ បានទទួលតំណែង ព្រះរាជាគណៈថ្នាក់ពិសេស ព្រះមហាសាសនវង្សាធិបតី មេគណក្រុងភ្នំពេញ, អគ្គាធិការរង នៃពុទ្ធិកសិក្សា,សមាជិកគណៈកម្មការវេយ្យាករណ៍ខ្មែរក្រសួងអប់រំជាតិ ។ល។

-សម័យ ប៉ុល ពត គេបង្ខំឲ្យលាសិក្ខា ទៅជាទាសករ... សម័យ យួនឈ្លានពាន បានចូលបួសវិញ គេឲ្យបុណ្យសក្តិខ្លះដែរ ជាសមាជិកគណៈកម្មការសង្ឃរដ្ឋធានី, គណៈកម្មការត្រួតពិនិត្យ ការបោះពុម្ពសៀវភៅធម៌ និង ការសម្ដែងធម៌... តែខ្ញុំមិនពេញចិត្ត នឹងបម្រើយួនទេ ។

-មកព្យាបាលរោគនៅប្រទេសបារាំង មានគេមកស្នើសុំប្រវត្តិរូប ដើម្បីឲ្យតំណែងដែរ តែខ្ញុំ មិនទទួល ៕

បោះពុម្ពនៅវត្តពោធិវង្ស

101,Boulevard de la République
77420 CHAMPS SUR MARNE
Tél : 01 60 06 44 98
Fax : 01 64 62 17 41

# ខ្មែរជិតធ្លាក់ខ្លួន

ខ្មែរជិតធ្លាក់ខ្លួនខ្ញុំគេហើយ　បងប្អូនខ្មែរអើយគិតយ៉ាងម៉េច
អ្នកដឹកនាំខ្លះបែបលោកភ្លេច　ព្រោះចង់ធ្វើស្តេចធ្វើនាយក.. ។
ស្តេចខ្លះលោកមិនបានភ្លេចទេ　តែមន្ត្រីខ្មែរខ្លះគម្រក់
ព្រោះតែចង់បានធ្វើនាយក　សុខចិត្តព្រមលក់ដីឲ្យយួន ។
ឯករាជ្យមានតែសម្បកក្រៅ　ខ្មែរខ្លះល្ងង់ខ្លៅមិនដឹងខ្លួន
នឹកស្មានថាខ្មែរនៅម៉ាំមួន　តែពិតពួកយួនក្តាប់ពីលើ ។
អ្នកខ្លះសប្បាយនឹងបុណ្យសក្តិ　បានមាសបានប្រាក់មិនចង់រើ
នឹកស្មានថាខ្លួនឯងគ្រាន់បើ　មិនដឹងជាភ្លើកញ្ញះគេ ។
បើយើងសម្ងំតាមពួកនេះ　យើងមិនខំរិះរើខ្លួនទេ
ជាតិយើងនឹងទៅជាខ្ញុំគេ　ថ្ងៃមុខងាករេលែងបានហើយ ។
គេភ្ញាក់រើខ្លួនគ្រប់តែគ្នា　ម្តេចកម្ពុជានៅកន្តើយ
បើអ្នកមិនព្រមរើខ្លួនហើយ　តើអ្នកណាឡើយរើជួសអ្នក ។
រស់នៅខ្ញុំគេគ្មានតម្លៃ　បើទុកជាក្សយថ្ងៃអនត្ប
ឬជាជូនជាតិដោយក្តីស្ម័គ្រ　ជាតិចងចាំជាក់ទុកមិនភ្លេច ។
ជាតិណាក៏គេលះបង់ដែរ　ម្តេចយើងជាតិខ្មែរបែរកលគេច
តើឲ្យគេយល់ថាយ៉ាងម៉េច　ទុកខ្មែរជាពេជ្រ ឬដុំក្រួស ។
ដូចនេះជាតិខ្មែរទាំងប្រុសស្រី　អ្នកស្រុកភូមិក្តី ឬអ្នកបួស
កុំទុកឲ្យពេលវាដើរហួស　យើងគ្មានអ្វីជួសជុលបានឡើយ ។
ភ្ញាក់ឡើងក្រោកឡើងរើបម្រះ　ទាំងក្មេងទាំងចាស់កុំកន្តើយ
រំដោះជាតិយើងរួចផុតហើយ　ទុក្ខខ្មែរបានស្បើយសុខសាន្តហោង ៕